# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ៣




វត្តនិគ្រោធវ័ន "គល់ទទឹង"

# អភិធម្មត្ថសង្គហៈ

# បរិច្ឆេទទី ៣

*រៀបរៀងដោយ*

**ភិក្ខុ អគ្គធីរោ គង់ សុមិត្ត**

*ព.ស. ២៥៥៥*

ឈ្មោះសៀវភៅ **អភិធម្មត្ថសង្គហៈ បរិច្ឆេទទី៣**

រៀបរៀងដោយ ភិក្ខុ **អគ្គធីរោ គង់ សុមិត្ត**

ផ្ទៀងផ្ទាត់ដោយ លោកម្ចាស់គ្រូ មេត្តាបាលោ

| | |
|---|---|
| ភិក្ខុ សាន សប្បាយ | សាមណេរ រឿន សារិទ្ធិ |
| ភិក្ខុ គូ សុភាព | សាមណេរ ម៉ៃ ភារា |
| ភិក្ខុ ប្រេម លីម | សាមណេរ សឿន សាន |
| ភិក្ខុ ឌឿ វុទ្ធី | សាមណេរ សុខ លាត |
| សាមណេរ លឹម ណារ៉ុម | សាមណេរ ហេង លឹមហាង |

កាលបរិច្ឆេទ ព.ស. ២៥៥៥

ស្ថានទីធ្វើ ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន "គល់ទទឹង" សង្កាត់ព្រែកថ្មី ខណ្ឌមានជ័យ រាជធានីភ្នំពេញ

# សម្ដែងព្រះអភិធម្ម នៅឋានតាវត្តិង្ស

កាលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ចាំព្រះវស្សាទី៧ នៅឋានតាវត្តិង្សទេវលោក ក្នុងគ្រាដែលបានសំដែងយមកបាដិហារ្យផ្ចាញ់ពួកតិរ្ថិយរួចហើយ បានគង់លើសិលាសនៈ ឈ្មោះបណ្ឌុកម្ពល ក្រោមដើមបារិឆត្ត ទ្រង់ព្រះសិរីសោភា ដូចព្រះអាទិត្យឧទ័យឡើងលើភ្នំយុគន្ធរ ដែលពួកនៃទេវតាទាំងឡាយក្នុងម៉ឺនចក្រវាឡបានមកប្រជុំគ្នា ហែហមសម្ដេចព្រះបរមសាស្ដាចារ្យ ទ្រង់ធ្វើសន្ទុសិតទេវបុត្រដែលធ្លាប់ជាពុទ្ធមាតា ឱ្យជាប្រធាននៃពួកទេវតាទាំងឡាយ ហើយត្រាស់កថាមគ្គព្រះអភិធម្មថា "**កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា**"ជាដើម ទ្រង់សម្ដែងដោយន័យនេះ ជាប់តរហូតអស់មួយព្រះវស្សា ដោយតេជៈនៃព្រះសព្វញ្ញុតញ្ញាណនោះ ។ ក៏កាលដែលទ្រង់សម្ដែងធម៌នោះ ក្នុងវេលាភិក្ខាចារទ្រង់និម្មិតព្រះពុទ្ធនិមិត្តដោយទ្រង់អធិដ្ឋានថា "ព្រះពុទ្ធនិមិត្ត

នេះ ចូរសម្ដែងធម៌ ឈ្មោះប៉ុណ្ណោះ ដរាបដល់តថាគតមក” ហើយក៏ស្ដេចយាងទៅព្រៃហេមពាន្ត ទ្រង់ទំពាឈើស្ទន់ ឈ្មោះនាគលតា ខ្ពុរព្រះឱស្ឋក្នុងស្រះអនោតត្ត នាំបិណ្ឌបាត អំពីឧត្តរកុរុទ្វីប បានធ្វើភត្តកិច្ចក្នុងរោងជំទូលាយហើយ ។ ព្រះសារីបុត្រទៅធ្វើវត្តចំពោះព្រះសាស្ដាក្នុងទីនោះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជាទេវតារបស់ទេវតា ជាអ្នកនាំវិសេសអង្គនោះ កាលទ្រង់សំដែងអភិធម្មណា ដល់ទេវតាទាំងឡាយហើយ ក៏បានត្រាស់ប្រាប់ដល់ព្រះសារីបុត្តត្ថេរ អ្នកឧបដ្ឋាកព្រះមហេសីជាម្ចាស់ ក្នុងអនោតត្តស្រះ ដោយន័យ (សង្ខេប)ទៀតថា “ម្នាលសារីបុត្រ ថ្ងៃនេះតថាគតបាន សម្ដែងធម៌ឈ្មោះប៉ុណ្ណោះ អ្នកចូរប្រាប់ដល់(ភិក្ខុ ៥០០) ជាកូនសិស្សរបស់អ្នក” ព្រះថេរៈបានស្ដាប់ហើយ ក៏បាន និមន្តមកកាន់លំនៅឋាន ហើយប្រាប់ដល់ភិក្ខុទាំងឡាយ, ព្រះអភិធម្មនោះ ដែលភិក្ខុទាំងឡាយបានទ្រទ្រង់ចាំទុកហើយ ដោយប្រការយ៉ាងនេះ ។

# ជីវប្រវត្តិសង្ខេប

ភិក្ខុ **គង់-សុមិត្ត** គង់នៅពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន គល់ទទឹង

ញោមប្រុស ឈ្មោះ គង់-តិក(ស្លាប់) ញោមស្រី ឈ្មោះ ហុក-តាង រស់នៅក្នុងភូមិខ្វិត ឃុំព្រែកខ្ពប ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

កើតនៅថ្ងៃព្រហស្បតិ៍ ៩ កើត ខែមិគសិរ ឆ្នាំ ថោះ ព.ស. ២៥១៩ - គ.ស. ១៩៧៦ ។ មានបងប្អូន ៧ នាក់ គឺ ប្រុស ៥ នាក់ ស្រី ២ នាក់. ជាកូនពៅ

ក្នុងកុមារ បានចូលរៀនសាលារដ្ឋ (ក្តាំងផា និង ព្រែកហ្លួង)ដល់ថ្នាក់ទី ៨ ។

ក្នុងព.ស.២៥៣៧ មានអាយុ១៩ឆ្នាំ បួសជាសាមណេរ ក្នុងសំណាក់ឧបជ្ឈាយ៍ ព្រះនាម ឡយ-លឿង វត្តស្លាកែត មកគង់នៅវត្តក្តាំងផា ខេត្តបាត់ដំបង ។

ព.ស. ២៥៣៨ មានអាយុគ្រប់ ២០ បានឧបសម្បទាជាភិក្ខុភាវៈ ។ ព.ស. ២៥៣៩ មកគង់នៅវត្តសមសាន្ត (ខេត្តបាត់ដំបង) រៀនវិន័យ-អភិធម្ម ។ ព.ស. ២៥៤០ មកនៅវត្តនិគ្រោធវ័ន ខេត្តកណ្តាល រៀនធម៌វិន័យបន្ត ។ ព.ស. ២៥៤១ ចេញទៅគង់នៅវត្តខេមវ័ន (ខេត្តកំចាម) បង្រៀនធម៌វិន័យ ។ ព.ស. ២៥៤៥ បានត្រឡប់មកវត្តនិគ្រោធវ័នវិញហើយលាសិក្ខា បានខិតខំ រៀបចំ និងជួយសរសេរសៀវភៅធម៌-វិន័យ ។ ព.ស. ២៥៤៦ បានបួសជាសាមណេរវិញទៀត ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ព្រះនាម ឃី-ទិត វត្តកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល បានជួយបង្រៀនព្រះវិន័យដល់ព្រះសង្ឃ ក្នុងវត្តនិគ្រោធវ័ន ។ ព.ស. ២៥៤៧ បានឧបសម្បទាជាភិក្ខុ បានបង្រៀនព្រះវិន័យដល់ព្រះសង្ឃ បង្រៀនអភិធម្មដល់ដូនជី ក្នុងវត្តនិគ្រោធវ័ន និងខិតខំរៀបចំសៀវភៅធម៌-វិន័យរហូតមក ។

# អភិធម្មត្ថសង្គហកថា

គម្ពីរអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ព្រះអនុរុទ្ធាចារ្យ បានចងក្រងឡើង ។

អភិធម្មត្ថសង្គហៈ មាន ៩ បរិច្ឆេទ គឺ

បរិច្ឆេទទី១ ចិត្តសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកចិត្ត ៨៩ ឬ១២១

បរិច្ឆេទទី២ ចេតសិកសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកចេតសិក ៥២

បរិច្ឆេទទី៣ បកិណ្ណកសង្គហៈ ការសម្ដែងសង្គ្រោះនិងចែកបកិណ្ណក ៦ ពួក

បរិច្ឆេទទី៤ វិថីសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកវិថីចិត្ត

បរិច្ឆេទទី៥ វិថីវិមុត្តសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកវិថីវិមុត្ត

បរិច្ឆេទទី៦ រូបសង្គហវិភាគ-និព្វានបរមត្ថ ការសម្តែងសង្គ្រោះ
និងចែករូបនិងនិព្វាន

បរិច្ឆេទទី៧ សមុច្ចយសង្គហវិភាគ ការសម្តែងសង្គ្រោះនិង
ចែកពួកធម៌ជាក្រុម ៗ

បរិច្ឆេទទី៨ បច្ចយសង្គហវិភាគ ការសម្តែងសង្គ្រោះនិង
ចែកបច្ច័យ១២ និង២៤

បរិច្ឆេទទី៩ កម្មដ្ឋានវិភាគ ការសម្តែងចែកកម្មដ្ឋាន
៤០ និងវិបស្សនា ។

សៀវភៅអភិធម្មនេះ ព្រះអនុរុទ្ធាចារ្យបានប្រមូលចង ក្រងអំពីបិដក និងអដ្ឋកថា ហើយបានចែកជាបរិច្ឆេទតាម ប្រភេទនៃបរមត្ថធម៌ ដើម្បីងាយស្រួលក្នុងការសិក្សា គឺ បរិច្ឆេទទី១ សម្តែងចិត្តបរមត្ថ, បរិច្ឆេទទី២ សម្តែងចេតសិក បរមត្ថ, បរិច្ឆេទទី៣, ៤, ៥ សម្តែងចិត្តបរមត្ថ និងចេតសិក បរមត្ថរួមគ្នា, បរិច្ឆេទទី ៦ សម្តែងរូបបរមត្ថ, និងនិព្វាន បរមត្ថ, បរិច្ឆេទទី៧, ៨, ៩ សម្តែងបរមត្ថទាំង ៤ រួមគ្នា ។

# បុព្វកថា

សៀវភៅអភិធម្មនេះ ខ្ញុំបានសរសេរក្នុងព.ស. ២៥៤៥ ចប់នៅក្នុងព.ស. ២៥៤៧ ។ ព.ស. ២៥៥២ បានរៀបចំជាសៀវភៅធំ ឈ្មោះថា អភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ។ ព.ស. ២៥៥៥ ដោយសេចក្ដីត្រូវរបស់អ្នកសិក្សា ក៏បានចែកតាមបរិច្ឆេទនីមួយ ៗវិញ ដើម្បីងាយកាន់សិក្សា ។

ការរៀបចំសៀវភៅអភិធម្មត្ថសង្គហៈនេះ បានចប់សព្វគ្រប់ ហើយ បើមានពាក្យឬសេចក្ដីណានៅខុស ក៏សូមអភ័យទោស និងសូមមេត្តាកែ សម្រួលផងចុះ ។

គម្ពីរព្រះអភិធម្ម ជាគម្ពីរដែលសម្ដែងឡើងនូវធម៌ពិត គឺ សច្ចធម៌ បរមត្ថធម៌ និងបង្ហាញនូវផ្លូវបដិបត្តិឆ្ពោះទៅរកទីរំលត់ទុក្ខ គឺ ព្រះនិព្វាន ។ សត្វលោកដែលកើតមកសុទ្ធតែមានអវិជ្ជា និងតណ្ហាគ្រប់គ្នា មានតែព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធទេ ដែលអាចត្រាស់ដឹងនូវធម៌ពិត កម្ចាត់អវិជ្ជាបានដោយខ្លួនព្រះអង្គឯង ក្រៅពីនោះ ត្រូវតែអាស្រ័យ

ព្រះពុទ្ធ ដែលទ្រង់មានព្រះទ័យមហាករុណាសម្ដែងប្រាប់ ទើបអាចយល់ដឹងស្គាល់ធម៌ពិត និងបានឃើញផ្លូវបដិបត្តិដល់ព្រះនិព្វានជាទីរំលត់ទុក្ខបាន ។

កាលបើពុទ្ធបរិស័ទទាំងអស់ សិក្សានូវព្រះអភិធម្មបានយល់ដឹងហើយ បញ្ញាក៏កើតឡើង បានឃើញនូវសភាវធម៌ពិតទាំងដែលយើងសព្វថ្ងៃបានជួប បានទាន់ព្រះធម៌កំពុងឋិតនៅសម្រាប់ក្រេបជញ្ជក់ធម្មរស ហើយធ្វើឱ្យយើងមានសម្រស់ក្នុងជីវិត មិនឋិតនៅក្នុងភាពស្ងិតស្រពោន និងសម្រេចមគ្គផលតាមឧបនិស្ស័យដែលយើងបានសន្សំមក, ព្រោះហេតុដូច្នេះទើបខ្ញុំព្យាយាមរៀបចំសៀវភៅនេះឡើង ។ម្យ៉ាងទៀត សៀវភៅនេះ ក៏ដូចជាសាវកមួយអង្គដែលឈ្លាសវៃនាំយកព្រះពុទ្ធដីកាមកប្រាប់ ហើយពន្យល់សេចក្ដីនោះ ឱ្យយើងបានយល់ដឹងឬចាត់ថា ជាគ្រូក៏បាន ។

ការរៀបចំសៀវភៅធម៌នេះ ជាបុណ្យកុសលមួយ

យ៉ាងល្អប្រសើរ ដែលខ្ញុំព្រះករុណា អាត្មាភាព និងពុទ្ធបរិស័ទទាំងឡាយ បានរួបរួមសាមគ្គីជួយឧបត្ថម្ភ ដោយកម្លាំងកាយចិត្ត និងថវិកា ជាចេតនាមហាកុសលថ្នាក់ធម្មទាន និងធម្មបូជា យ៉ាងពេញចិត្តគ្រប់ ៗគ្នា ។ ដោយអំណាចនៃបុណ្យនេះ នឹងនាំឱ្យបានទទួលនូវសេចក្ដីសុខ ជាពិសេស គឺបាននូវបញ្ញាដែលជាពន្លឺញាំងជីវិតឱ្យរុងរឿងគ្រប់ ៗ ជាតិរហូតដល់បានលះបង់នូវមន្ទិលគឺ កិលេស ដែលយើងគ្រប់ ៗ គ្នាចង់បាននូវ ការត្រាស់ដឹងនូវសច្ចធម៌ ឃើញច្បាស់នូវព្រះនិព្វាន ដែលជាទីបំផុតទុក្ខ ។ ម្យ៉ាងទៀត បញ្ញានេះឯង អាចឱ្យសម្រេចតាមសេចក្ដីប្រាថ្នានោះបាន ។

ខ្ញុំព្រះករុណាអាត្មាភាព សូមអនុមោទនានូវបុណ្យកុសលរបស់ពុទ្ធបរិស័ទ ទាំងអស់ ដែលបានឧបត្ថម្ភថវិកាជាធម្មទាន និងការខិតខំសិក្សានេះ ។ ម្យ៉ាងទៀត សូមពុទ្ធ

បរិស័ទទាំងអស់ អនុមោទនាយកនូវបុណ្យដែលខ្ញុំព្រះករុណាអាត្មាភាព បានរៀបចំបោះពុម្ពព្រះអភិធម្មនេះផងចុះ ។ សូមឱ្យពុទ្ធបរិស័ទទាំងអស់ មានបញ្ញា ភ្លឺថ្លាមោះមុត ជាគ្រឿងត្រាស់ដឹងនូវសច្ចធម៌ សូមបានសម្រេចនូវសម្បត្តិលោកិយៈ និងលោកុត្តរៈ មានចិត្តល្អបរិសុទ្ធរួចផុតចាកទុក្ខដល់ព្រះនិព្វានគ្រប់ ៗ គ្នា កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអនុមោទនា !!!

ថ្ងៃ១៥កើត ខែស្រាព ឆ្នាំថោះ ត្រីស័ក ព.ស.២៥៥៥

# បញ្ជីមាតិកា អភិធម្មត្ថសង្គហៈ

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**

*សម្ដេចព្រះអភិធម្ម នៅឋានតាវត្តិង្ស ... ... ... ... ... ក*

*ជីវប្រវត្តិសង្ខេបគ ... ... ... ... ... ... ... ... ... ... ... ... គ*

*អភិធម្មត្ថសង្គហកថា ... ... ... ... ... ... ... ... ... ... ... ង*

*បុព្វកថា ... ... ... ... ... ... ... ... ... ... ... ... ... ... ... ឆ*

*បញ្ជីមាតិកា ... ... ... ... ... ... ... ... ... ... ... ... ... ... ជ*

**អភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៣ បកិណ្ណកសង្គហៈ**

*សង្គហគាថាទី១-២ សង្គហៈ ៦ ... ... ... ... ... ... ... ... ១*

*អធិប្បាយ ... ... ... ... ... ... ... ... ... ... ... ... ... ២*

*បកិណ្ណកសង្គហៈ មាន ៦ ... ... ... ... ... ... ... ... ៣*

*១-វេទនាសង្គហៈ ... ... ... ... ... ... ... ... ... ... ... ៤*

*សង្គហគាថាទី៣-៤ ... ... ... ... ... ... ... ... ៤*

*អធិប្បាយ វេទនា ២ ន័យ ... ... ... ... ... ៥*

*ចែកចិត្ត ១២១ ដោយវេទនា ៣ ... ... ... ៥*

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**

ចែកចិត្ត ១២១ ដោយវេទនា ៥ ... ... ... ៦
លក្ខណៈរបស់វេទនា ៥ ... ... ... ... ... ... ៧
វេទនាកើតជាមួយនឹងចេតសិក ... ... ... ... ៨
វេទនា ៥ កើតរួមជាមួយនឹងចេតសិក ... ... ៨
ចេតសិកកើតរួមនឹងវេទនា ... ... ... ... ... ... ៩
សម្ដែងវេទនា៣ឬ៥ កើតក្នុងចិត្ត១២១ ... ... ១១
២-ហេតុសង្គហៈ ... ... ... ... ... ... ... ... ... ... ... ១៣
សង្គហគាថាទី៥-៦ ... ... ... ... ... ... ... ... ១៣
អធិប្បាយហេតុសង្គហៈ ... ... ... ... ... ... ... ១៤
ចែកចិត្តដោយហេតុ ៦ ... ... ... ... ... ... ... ១៥
អហេតុកចិត្តនេះ មាន ១៨ គឺ - ... ... ... ១៥
សហេតុកចិត្តនេះ មាន ៣ ពួក គឺ - ... ... ១៦
ចែកហេតុដោយន័យផ្សេង ៗ ... ... ... ... ... ១៧
សម្ដែងចេតសិកដោយហេតុ ... ... ... ... ... ១៩

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


ការសង្គ្រោះចេតសិក ដោយហេតុ ... ... ... ២០

ការរាប់ហេតុក្នុងចិត្តប្បាទដោយពិស្តារ ... ... ២២

សរុបការរាប់ចិត្ត ៨៩ ... ... ... ... ... ... ... ២៤

៣-កិច្ចសង្គហៈ ... ... ... ... ... ... ... ... ... ... ... ... ២៥

សង្គហគាថាទី៧-៨ ... ... ... ... ... ... ... ... ២៥

អធិប្បាយកិច្ចសង្គហៈ ... ... ... ... ... ... ... ២៦

កិច្ចរបស់ចិត្ត មាន ១៤ យ៉ាង ... ... ... ... ២៧

អធិប្បាយចិត្តធ្វើកិច្ច ១៤ យ៉ាង ... ... ... ... ២៨

កិច្ចដោយពិស្តារមាន ២ ន័យ ... ... ... ... ៣១

ចិត្តធ្វើកិច្ចដោយពិស្តារ ៥ ន័យ ... ... ... ... ៣១

ចេតសិកធ្វើកិច្ច ដោយពិស្តារ ៧ ន័យ ... ៣៣

សរុបចិត្តធ្វើកិច្ច ៥ ន័យ ... ... ... ... ... ... ៣៧

សរុបចេតសិកធ្វើកិច្ច ៧ ន័យ ... ... ... ... ៣៨

ឋានចៃចិត្ត មាន ១០ ឋាន ... ... ... ... ... ៣៨

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


អធិប្បាយឋាន ១០ យ៉ាង ... ... ... ... ... ... ៤០

៤-ទ្វារសង្គហៈ ... ... ... ... ... ... ... ... ... ... ... ... ៤៣

ទ្វារសង្គហៈ មាន ៦ យ៉ាង ... ... ... ... ... ៤៣

អធិប្បាយ ទ្វារសង្គហៈ ... ... ... ... ... ... ... ៤៤

សង្គហគាថាទី៩-១០ ... ... ... ... ... ... ... ... ៤៥

ចែកចិត្តដោយពិស្តារ ... ... ... ... ... ... ... ... ៤៧

៥-អារម្មណសង្គហៈ ... ... ... ... ... ... ... ... ... ... ៥១

អារម្មណ៍មាន ៦ យ៉ាង ... ... ... ... ... ... ... ៥២

អធិប្បាយអារម្មណ៍ ៦ មានរូបជាដើម ... ... ៥៣

ឥដ្ឋារម្មណ៍ មាន ២ យ៉ាង ... ... ... ... ... ៥៥

សម្ដែងទ្វារិកចិត្ត ដោយអារម្មណ៍ ៦ ... ... ៥៦

តិកាលិក និងកាលវិមុត្ត ... ... ... ... ... ... ... ៥៧

ទ្វារវិមុត្តចិត្តមានអារម្មណ៍ ៣ យ៉ាង ... ... ... ៥៨

អារម្មណ៍ ៤ ដោយសង្ខេប ... ... ... ... ... ៥៩

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ


ចិត្តមានអារម្មណ៍ជាឯកន្តៈនិងអនេកន្តៈ ... ... ៦០

សង្គហគាថាទី១១-១២ ... ... ... ... ... ... ... ៦១

សរុបឯកន្តៈ និងអនេកន្តៈ ... ... ... ... ... ... ៧២

អារម្មណ៍ដោយពិស្តារ ២១ យ៉ាង ... ... ... ៧៣

ចិត្តទទួលអារម្មណ៍ដោយពិស្តារ ... ... ... ... ៧៦

សរុបចិត្តទទួលអារម្មណ៍ ៨ ន័យ ... ... ... ៨៥

អធិប្បាយចិត្តដែលដឹងអារម្មណ៍៨ន័យ ... ... ៨៧

៦-វត្ថុសង្គហៈ ... ... ... ... ... ... ... ... ... ... ... ... ៩០

សង្គហគាថាទី១៣-១៤ ... ... ... ... ... ... ... ៩១

អធិប្បាយ ... ... ... ... ... ... ... ... ... ... ... ៩២

សង្គហគាថា ... ... ... ... ... ... ... ... ... ... ៩៤

ចេតសិក ៥២ ... ... ... ... ... ... ... ... ... ... ៩៧

អវសានគាថា ... ... ... ... ... ... ... ... ... ... ៩៩

សម្តែងបកិណ្ណកសង្គហៈ ៦ យ៉ាង ... ... ... ១០០

# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ៣ បកិណ្ណកសង្គហៈ

*នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។*

*អភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៣ ឈ្មោះបកិណ្ណកសង្គហៈ នេះ មានសង្គហគាថាដែលព្រះអនុរុទ្ធាចារ្យបង្ក្រងទុក ១៤ គាថា, ដើម្បីសម្តែងធម៌ ៦ យ៉ាង គឺ វេទនា ហេតុ កិច្ច ទ្វារ អារម្មណ៍ និង វត្ថុ គប្បីជ្រាបសង្គហគាថាទាំង ១៤ នោះ ដូចតទៅនេះ ៖*

### សង្គហគាថា

១. សម្បយុត្តា យថាយោគំ តេបញ្ញាស សភាវតោ
ចិត្តចេតសិកា ធម្មា តេសន្ទានិ យថារហំ ។

*ធម៌ គឺ ចិត្ត និងចេតសិក ៥៣ យ៉ាង ដែលសម្បយុត្តគ្នាតាមគួរដល់ការប្រកប ដោយភាវៈរបស់ខ្លួន ៗ ។*

២. វេទនាហេតុតោ កិច្ច ទ្វារាលម្ពនវត្ថុតោ
ចិត្តុប្បាទវសេនេវ សង្គហោ នាម នីយតេ ។

*ឥឡូវនេះ ខ្ញុំនឹងពោលនូវចិត្តនិងចេតសិកចូលគ្នាដោយសង្គហ៦ គឺ វេទនា ហេតុ កិច្ច ទ្វារ អារម្មណ៍ និងវត្ថុ សម្តែងចេញឱ្យច្បាស់ដោយអំណាចចិត្តុប្បាទ តាមសមគួរ ។*

## អធិប្បាយ

*ពាក្យថា **បកិណ្ណកសង្គហ** ចែកស័ព្ទជា **បកិណ្ណក** + **សង្គហ**; **បកិណ្ណកៈ** ប្រែថា ខ្ចាត់ខ្ចាយ បន្តិចបន្តួច និងរាយរង ។ **សង្គហៈ** ប្រែថា ការរួបរួម ការសង្គ្រោះ ការប្រមូល ការបំពេញ ។ ធម៌ គឺ ចិត្ត និងចេតសិក រួម ៥៣ យ៉ាងនោះ បានដល់ ចិត្ត ១ ចេតសិក ៥២ ជាការរាប់ដោយសភាវៈ ឬដោយលក្ខណៈតែមួយយ៉ាង គឺ ចិត្ត ៨៩ ឬចិត្ត ១២១ ក៏ដោយ កាលរាប់ដោយលក្ខណៈ ក៏មានត្រឹមតែមួយយ៉ាង ដូចព្រះបាលីថា ៖*

***អារម្មណវិជាននលក្ខណំ ចិត្តំ*** : ចិត្តមានការដឹងអារម្មណ៍ជាលក្ខណៈ ។

ចំណែកចេតសិក ៥២ នោះ មានលក្ខណៈរាប់បាន ៥២ លក្ខណៈ ព្រោះហេតុនេះ ទើបលោកពោលថា ចិត្ត និងចេតសិក ៥៣ យ៉ាង ដូច្នេះ ។

## បកិណ្ណកសង្គហៈ មាន ៦

**១-វេទនាសង្គហៈ** ការសង្គ្រោះចិត្តចេតសិកដោយវេទនា ៣ ឬ៥
**២-ហេតុសង្គហៈ** ការសង្គ្រោះចិត្តចេតសិកដោយហេតុ ៦
**៣-កិច្ចសង្គហៈ** ការសង្គ្រោះចិត្តចេតសិកដោយកិច្ច ១៤
**៤-ទ្វារសង្គហៈ** ការសង្គ្រោះចិត្តចេតសិកដោយទ្វារ ៦
**៥-អារម្មណសង្គហៈ** ការសង្គ្រោះចិត្តចេតសិកដោយអារម្មណ៍៦
**៦-វត្ថុសង្គហៈ** ការសង្គ្រោះចិត្តចេតសិកដោយវត្ថុ ៦

បណ្តាសង្គហៈទាំង ៦ នេះ សង្គហៈនីមួយ ៗ លោកសម្តែងដោយចិត្តុប្បាទ ដែលកើតឡើងហើយដោយធម៌ មានវេទនាជាដើម ។

## ១-វេទនាសង្គហៈ

### សង្គហគាថា

៣. សុខំ ទុក្ខមុបេក្ខាតិ តិវិធា តត្ថ វេទនា
សោមនស្សំ ទោមនស្សំ ឥតិ ភេទេន បញ្ចធា ។

៤. សុខមេកត្ថ ទុក្ខញ្ច ទោមនស្សំ ទ្វយេ ឋិតំ
ទ្វាសដ្ឋីសុ សោមនស្សំ បញ្ចបញ្ញាសកេតរា ។

*ក្នុងវេទនាសង្គហៈនោះ ពោលដោយអារម្មណានុភវនលក្ខណន័យ បានវេទនា ៣ គឺ សុខវេទនា ទុក្ខវេទនា និងឧបេក្ខាវេទនា. ពោលដោយឥន្ទ្រិយភេទន័យ បានវេទនា ៥ គឺ សុខ ទុក្ខ សោមនស្ស ទោមនស្ស និងឧបេក្ខា. ក្នុងវេទនាទាំងនេះ សុខនិងទុក្ខ តាំងនៅក្នុងចិត្តមួយ គឺ កាយវិញ្ញាណ, ទោមនស្ស តាំងនៅក្នុងចិត្ត២ គឺ ទោសមូលចិត្ត២, សោមនស្សតាំងនៅក្នុងចិត្ត ៦២ ចំណែកឧបេក្ខាក្រៅនេះ តាំងនៅក្នុងចិត្ត៥៥ ។*

## អធិប្បាយ វេទនា ២ ន័យ

ន័យទី ១ សម្តែងវេទនាដោយលក្ខណៈដែលសោយអារម្មណ៍ សំដៅដល់ការសោយអារម្មណ៍ប៉ុណ្ណោះ មិនបានចែកប្រភេទទៅតាមលក្ខណៈដែលជាឥន្ទ្រិយ, វេទនានេះ ទើបមាន ៣ គឺ សុខវេទនា ទុក្ខវេទនា និងឧបេក្ខាវេទនា ហៅថា អារម្មណានុភវនលក្ខណន័យ ។

## ចែកចិត្ត ១២១ ដោយវេទនា ៣

១-ចិត្តដែលកើតជាមួយនឹងសុខវេទនាសោមនស្សវេទនាមាន ៦៣ គឺ សុខសហគតកាយវិញ្ញាណ ១

សោមនស្សសហគតចិត្ត ៦២

២-ចិត្តដែលកើតជាមួយនឹងទុក្ខវេទនា ទោមនស្សវេទនាមាន ៣ គឺ ទុក្ខសហគតកាយវិញ្ញាណ ១

ទោមនស្សសហគតចិត្ត ២

៣-ចិត្តដែលកើតជាមួយនឹងឧបេក្ខាវេទនា មាន ៥៥ គឺ

កាមឧបេក្ខាចិត្ត ៣២

រូបាវចរបញ្ចមជ្ឈានចិត្ត ៣

អរូបាវចរឈានចិត្ត ១២

លោកុត្តរបញ្ចមជ្ឈានចិត្ត ៨

**ន័យទី ២** សម្ដែងវេទនាដោយប្រភេទនៃឥន្ទ្រិយ ៥ គឺ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ និង ឧបេក្ខិន្ទ្រិយ ហៅថា **ឥន្ទ្រិយភេទន័យ ។**

**ចែកចិត្ត ១២១ ដោយវេទនា ៥**

១-សុខវេទនា កើតជាមួយនឹងកាយវិញ្ញាណចិត្ត ១

២-ទុក្ខវេទនា កើតជាមួយនឹងកាយវិញ្ញាណចិត្ត ១

៣-សោមនស្សវេទនា កើតជាមួយនឹងសោមនស្សចិត្ត ៦២ គឺ

កាមសោមនស្សចិត្ត ១៨ រូបាវចរសោមនស្សចិត្ត ១២

លោកុត្តរសោមនស្សចិត្ត ៣២

៤-ទោមនស្សវេទនា កើតជាមួយនឹងបដិឃសម្បយុត្តចិត្ត ២

៥-ឧបេក្ខាវេទនា កើតជាមួយនឹងចិត្ត ៥៥ គឺ

កាមឧបេក្ខាសហគត ៣២ រូបាវចរបញ្ចមជ្ឈានចិត្ត ៣

អរូបាវចរឈានចិត្ត ១២ លោកុត្តរបញ្ចមជ្ឈានចិត្ត ៨

## លក្ខណៈរបស់វេទនា ៥

**១-ឥដ្ឋផោដ្ឋព្វានុភវនលក្ខណំ សុខំ** សុខវេទនា មានការសោយផោដ្ឋព្វារម្មណ៍ដែលគួរប្រាថ្នា ជាលក្ខណៈ

**២-អនិដ្ឋផោដ្ឋព្វានុភវនលក្ខណំ ទុក្ខំ** ទុក្ខវេទនា មានការសោយផោដ្ឋព្វារម្មណ៍ ដែលមិនគួរប្រាថ្នា ជាលក្ខណៈ

**៣-សភាវតោ បរិកប្បតោ វា ឥដ្ឋានុភវនលក្ខណំ សោមនស្សំ** សោមនស្ស វេទនា មានការសោយអារម្មណ៍ដែលគួរប្រាថ្នា ដោយសភាវៈខ្លះ ដោយបរិកប្បខ្លះ ជាលក្ខណៈ

**៤-តថា អនិដ្ឋានុភវនលក្ខណំ ទោមនស្សំ** ទោមនស្សវេទនា មានការសោយអារម្មណ៍ដែលមិនគួរប្រាថ្នា ដោយសភាវៈខ្លះ ដោយបរិកប្បខ្លះ ដូចយ៉ាង(ទី៣)នោះ ជាលក្ខណៈ

**៥-មជ្ឈត្តានុភវនលក្ខណា ឧបេក្ខា** ឧបេក្ខាវេទនា មានការសោយ

អារម្មណ៍ ដែលជាកណ្តាល ជាលក្ខណៈ ។

## វេទនាកើតជាមួយនឹងចេតសិក

អាចារ្យពួកខ្លះ (ក្រៅព្រះបាលីអភិធម្មត្ថសង្គហៈ និងដីកា) ពោលវេទនា និងចេតសិកទុក ២ ន័យ គឺ

- វេទនាកើតរួមជាមួយនឹងចេតសិក ១
- ចេតសិកកើតរួមជាមួយនឹងវេទនា ១ ។

## វេទនា ៥ កើតរួមជាមួយនឹងចេតសិក

១-សុខ ឬទុក្ខ កើតរួមនឹងសព្វចិត្តសាធារណចេតសិក ៦ (វៀរវេទនា) ។

២-សោមនស្ស កើតរួមនឹងចេតសិក ៤៦ គឺ អញ្ញសមានាចេតសិក ១២ (វៀរវេទនា) អកុសលចេតសិក ៩ (វៀរទោចតុក្កៈ ៤ វិចិកិច្ឆា ១) សោភណចេតសិក ២៥ ។

៣-ទោមនស្ស កើតរួមនឹងចេតសិក ២១ គឺ អញ្ញសមានា

ចេតសិក ១១ (វៀរវេទនា បីតិ) អកុសលចេតសិក ១០ (វៀរលោភិកៈ ៣ វិចិកិច្ឆា ១)

៤-ឧបេក្ខាកើតរួមនឹងចេតសិក ៤៦ គឺ អញ្ញសមានាចេតសិក ១១ (វៀរវេទនា បីតិ) អកុសលចេតសិក ១០ (វៀរទោចតុក្កៈ ៤) សោភណចេតសិក ២៥ ។

## ចេតសិកកើតរួមនឹងវេទនា

១-ចេតសិកកើតរួមនឹងវេទនា ១ មាន ៦ គឺ បីតិ កើតរួមនឹងសោមនស្សវេទនាតែម្យ៉ាង

ទោចតុក្កៈ ៤ កើតរួមនឹងទោមនស្សវេទនាតែម្យ៉ាង

វិចិកិច្ឆា កើតរួមនឹងឧបេក្ខាវេទនាតែម្យ៉ាង

២-ចេតសិកកើតរួមនឹងវេទនា ២ មាន២៨ គឺ លោភិកៈ៣ និងសោភណចេតសិក២៥ (ទាំង២ពួកនេះ) កើតរួមនឹងសោមនស្សវេទនា ក៏បាន នឹងឧបេក្ខាវេទនា ក៏បាន

៣-ចេតសិកកើតរួមនឹងវេទនា ៣ មាន ១១ គឺ មោចតុក្កៈ ៤ ថីទុកៈ ២ វិតក្កៈ វិចារៈ អធិមោក្ខៈ វីរិយៈ និង

ឆន្ទៈ រួម ១១ ចេតសិកនេះ កើតរួមនឹងសោមនស្ស ទោមនស្ស និងឧបេក្ខាវេទនា យ៉ាងណាមួយ ក៏បាន ។

៤-ចេតសិកកើតរួមនឹងវេទនា ៥ មាន ៦ គឺ សព្វចិត្តសាធារណចេតសិក ៦ ( វៀរវេទនា )

៥-ចេតសិកដែលមិនកើតរួមនឹងវេទនា មាន ១ គឺ វេទនាចេតសិក ។

<u>ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក</u> ទ្រង់ត្រាស់អំពីវេទនាថា "ម្នាលអានន្ទ វេទនាពីរ ក៏តថាគតសំដែងដោយបរិយាយ, វេទនា ៣ ក៏តថាគតសំដែងដោយបរិយាយ, វេទនា ៤ ក៏តថាគតសំដែងដោយបរិយាយ, វេទនា ៥ ក៏តថាគតសំដែងដោយបរិយាយ, វេទនា ៦ ក៏តថាគតសំដែងដោយបរិយាយ, វេទនា ១៨ ក៏តថាគតសំដែងដោយបរិយាយ, វេទនា ៣៦ ក៏តថាគត សំដែងដោយបរិយាយ, វេទនា ១០៨

ក៏តថាគតសំដែងដោយបរិយាយ”[១] ។

## សម្តែង វេទនា ៣ ឬ ៥ កើតក្នុងចិត្ត ១២១

១. សុខវេទនា ៦៣

- ១. សុខិន្ទ្រិយ ១ - សុខសហគតកាយវិញ្ញាណ ១
- ៣. សោមនស្សិន្ទ្រិយ ៦២
  - កាមសោមនស្សិន្ទ្រិយ ១៨
    - សោមនស្សលោភមូលចិត្ត ៤
    - សោមនស្សសន្តីរណចិត្ត ១
    - សោមនស្សហសិតុប្បាទចិត្ត ១
    - សោមនស្សមហាកុសលចិត្ត ៤
    - សោមនស្សមហាវិបាកចិត្ត ៤
    - សោមនស្សមហាកិរិយាចិត្ត ៤
  - ឈានសោមនស្សិន្ទ្រិយ ៤៤
    - បឋមជ្ឈានចិត្ត ១១
    - ទុតិយជ្ឈានចិត្ត ១១
    - តតិយជ្ឈានចិត្ត ១១
    - ចតុត្ថជ្ឈានចិត្ត ១១

---

១. មជ្ឈិ. មជ្ឈិ. ពហុវេទនិយសូត្រ ២៣. ៩៩/១៦៤; វេទនា ២ គឺ សុខ និងទុក្ខ ។ វេទនា ៣ គឺ សុខ ទុក្ខ និងឧបេក្ខា ។ វេទនា ៤ មិនឃើញមានពន្យល់ ។ វេទនា ៥ គឺ វេទនិន្ទ្រិយទាំង ៥ ។ វេទនា ៦ គឺ វេទនាកើតអំពីចក្ខុសម្ផស្សជាដើម ។ វេទនា ១៨ គឺ វេទនា ៣ គុណនឹង

**២. ទុក្ខវេទនា ៣**

- ២. ទុក្ខិន្ទ្រិយ ១ - ទុក្ខសហគតកាយវិញ្ញាណ ១
- ៤.ទោមនស្សិន្ទ្រិយ២ - ទោមនស្សសហគតបដិឃចិត្ត ២

**៣. ឧបេក្ខាវេទនា**

**៥. ៤. ឧបេក្ខិន្ទ្រិយ ៥៥**

- កាមឧបេក្ខាចិត្ត៣២
  - ឧបេក្ខាលោភមូលចិត្ត ៤
  - ឧបេក្ខាមោហមូលចិត្ត ២
  - ឧបេក្ខាអហេតុកចិត្ត ១៤
  - ឧបេក្ខាមហាកុសលចិត្ត ៤
  - ឧបេក្ខាមហាវិបាក ៤
  - ឧបេក្ខាមហាកិរិយាចិត្ត ៤
- ឈានឧបេក្ខាចិត្ត២៣
  - រូបាវចរបញ្ចមជ្ឈានចិត្ត ៣
  - អរូបាវចរចិត្ត ១២
  - លោកុត្តរបញ្ចមជ្ឈានចិត្ត ៨

**ចប់ វេទនាសង្គហៈ**

---

អារម្មណ៍ ៦ ។ វេទនា ៣៨ គឺ គេហសិតសោមនស្ស ៦ គេហសិតទោមនស្ស ៦ គេហសិតឧបេក្ខា ៦ នេក្ខម្មសិតសោមនស្ស ៦ នេក្ខម្មសិតទោមនស្ស៦ នេក្ខម្មសិតឧបេក្ខា៦ ។ វេទនា១០៨ គឺ វេទនាទាំង ៣៦ នោះឯង ដែលជាអតីត ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ ។ អដ្ឋកថា ។

# ២_ហេតុសង្គហៈ

## សង្គហគាថា

៥. លោភោ ទោសោ ច មោហោ ច  ហេតូ អកុសលា តយោ
អលោភាទោសាមោហា ច  កុសលាព្យាកតា តថា ។

*អកុសលហេតុ មាន ៣ គឺ លោភៈ ១ ទោសៈ ១ និងមោហៈ ១ ។ កុសលហេតុ និងអព្យាកតហេតុ ក៏មាន ៣ ដូចគ្នា គឺ អលោភៈ ១ អទោសៈ ១ អមោហៈ ១ ។*

៦. អហេតុកដ្ឋារសេក  ហេតុកា ទ្វេ ទ្វិវីសតិ
ទ្វិហេតុកា មតា សត្ត  ចត្តាឡីស តិហេតុកា ។

*ចិត្តជាអហេតុកៈ ១៨ ចិត្តជាឯកហេតុកៈ ២, ចិត្តជាទុហេតុកៈ ២២, ចិត្តជាតិហេតុកៈ ៤៧ ។*

## **អធិប្បាយហេតុសង្គហៈ**

ការរួបរួមចិត្តុប្បាទដោយហេតុ ហៅថា **ហេតុសង្គហៈ** ។ ឈ្មោះថា ហេតុ ក្នុងហេតុសង្គហៈនោះ បានដល់ ចេតសិក ៦ យ៉ាង គឺ លោភៈ ទោសៈ មោហៈ និងអលោភៈ អទោសៈ អមោហៈ ។

**ហេតុ** មានវចនត្ថៈថា ៖

**ហិណោតិ បវត្តតិ ផលំ ឯតេនាតិ ហេតុ** ប្រែថា ផលរមែងកើតឡើងប្រព្រឹត្តទៅតាមធម៌នេះ ព្រោះហេតុនោះ ធម៌នេះ ឈ្មោះថា ហេតុ បានដល់ ធម៌ដែលជាគ្រឿងកើតឡើងនៃផល ។

ក៏សេចក្តីជាហេតុ គឺ សេចក្តីដែលធម៌ជាហេតុទាំងនោះ ជាឫសគល់ គឺ ញ៉ាំងសម្បយុត្តធម៌ទាំងឡាយ ឱ្យតាំងនៅមាំ ។ ពិតមែន ធម៌ទាំងឡាយ ដែលបានហេតុជាបច្ច័យហើយ រមែងជាសភាពរឹងមាំ ដូចដើមឈើមានឫសគល់លូតលាស់ល្អហើយ មិនដូចធម៌ដែលមិនមានហេតុ ដូចសារាយ ក្នុងផ្ទៃទឹក ដូច្នោះ ទើបពោលហេតុទាំង ៦ នេះថា "ជាឫសគល់ ដូចជាឫសឈើ" ។

## ចែកចិត្តដោយហេតុ ៦

ក្នុងគាថាទី ៥ លោកសម្តែងហេតុទាំងឡាយ ក្នុងគាថាទី ៦ នេះ លោកសម្តែងចិត្តទាំងឡាយថា ចិត្តអ្វីខ្លះ ដែលប្រកបដោយហេតុអ្វីខ្លះ ឬ មិនមានហេតុអ្វី ៗប្រកប ក៏ចិត្តទាំងអស់ ៨៩ ឬ ១២១ នោះ កាលចែកជាប្រភេទ មាន ២ ប្រភេទប៉ុណ្ណោះ គឺ ៖

១-អហេតុកចិត្ត មាន១៨ ២-សហេតុកចិត្ត មាន៧១

***អហេតុកចិត្ត*** ប្រែថា ចិត្តដែលមិនមានហេតុ គឺ ចិត្តដែលមិនមានហេតុណាមួយ( ក្នុងហេតុទាំង ៦ )កើតរួមនឹងចិត្តនោះទេ ។

## អហេតុកចិត្តនេះ មាន ១៨ គឺ -

បញ្ចទ្វារាវជ្ជនចិត្ត១ បញ្ចវិញ្ញាណ១០ វិបាកមនោធាតុ២ សន្តីរណចិត្ត៣ មនោទ្វារាវជ្ជនចិត្ត១ ហសិតុប្បាទចិត្ត១

***សហេតុកចិត្ត*** ប្រែថា ចិត្តដែលមានហេតុ គឺ ចិត្តដែលមានហេតុណាមួយ( ឬពីរបីក្នុងហេតុ៦ )កើតរួមនឹងចិត្ត ។

**សហេតុកចិត្តនេះ មាន ៣ ពួក គឺ -**

១-ឯកហេតុកចិត្ត បានដល់ ចិត្តដែលមានហេតុប្រកប ១

២-ទ្វិហេតុកចិត្ត បានដល់ ចិត្តដែលមានហេតុប្រកប ២

៣-តិហេតុកចិត្ត បានដល់ ចិត្តដែលមានហេតុប្រកប ៣

**ឯកហេតុកចិត្ត** ចិត្តមានមោហហេតុប្រកបតែម្យ៉ាង គឺ វិចិកិច្ឆាសម្បយុត្តចិត្ត ១ ឧទ្ធច្ចសម្បយុត្តចិត្ត ១ លោកហៅ ចិត្ត ២ នេះ ថា "មោហមូលចិត្ត២ៈ មោមូហចិត្ត២ៈ មោហចិត្ត២ៈ" ។

**ទ្វិហេតុកចិត្ត** ជាចិត្តដែលមានហេតុ ២ កើតរួមនឹងចិត្ត ។ ចិត្តនេះ មាន ២២ គឺ

លោភមូលចិត្ត ៨ មានលោភហេតុ និងមោហហេតុកើតរួម, ទោសមូលចិត្ត ២ មានទោសហេតុ និងមោហហេតុកើតរួម, មហាកុសលចិត្ត ៤ មហាវិបាកចិត្ត ៤ មហាកិរិយាចិត្ត ៤ ដែលជាញាណវិប្បយុត្ត មាន

អលោភហេតុ និងអទោសហេតុកើតរួមគ្នា ។

**តិហេតុកចិត្ត** ជាចិត្តដែលមានសោភណហេតុទាំង ៣ គឺ អលោភហេតុ អទោសហេតុ និងអមោហហេតុកើតរួម

តិហេតុកចិត្តនេះ មាន ៤៧ឬ៧៩ គឺ

មហាកុសលញាណសម្បយុត្តចិត្ត ៤, មហាវិបាកញាណសម្បយុត្តចិត្ត ៤,

មហាកិរិយាញាណសម្បយុត្តចិត្ត ៤, មហគ្គតចិត្ត ២៧, លោកុត្តរចិត្ត ៨ឬ៤០

## ចែកហេតុដោយន័យផ្សេង ៗ

***១-ដោយន័យ នៃអសោភណហេតុ និងសោភណហេតុ គឺ***

អសោភណហេតុ បានលោភៈ ទោសៈ មោហៈ ដែលកើតរួមនឹងអកុសលចិត្ត ១២ តាមសមគួរ ។

សោភណហេតុ បានអលោភៈ អទោសៈ អមោហៈ ដែលកើតរួមនឹងសោភណចិត្ត ៥៩ តាមសមគួរ ។

**២-ដោយធម៌** មាន ៣ គឺ

ដែលជាអកុសលហេតុ បានលោភៈ ទោសៈ មោហហេតុ កើតរួមនឹងអកុសលចិត្ត ១២ តាមសមគួរ ។

ដែលជាកុសលហេតុ បានអលោភៈ អទោសៈ អមោហហេតុ កើតរួមនឹងកុសលចិត្ត ២១ តាមសមគួរ ។

ដែលជាអព្យាកតហេតុ បានអលោភៈ អទោសៈ អមោហហេតុដែលកើតរួមនឹងសហេតុកវិបាកចិត្ត ២១ និងសហេតុកកិរិយាចិត្ត ១៧ តាមសមគួរ ។

**៣- ដោយជាតិ** មាន ៤ គឺ

អកុសលជាតិ បានលោភៈ ទោសៈ មោហហេតុ

កុសលជាតិ បានអលោភៈ អទោសៈ អមោហហេតុ

វិបាកជាតិ បានអលោភៈ អទោសៈ អមោហហេតុ

កិរិយាជាតិ បានអលោភៈ អទោសៈ អមោហហេតុ

**៤- ដោយភូមិ** មាន ៤ គឺ

កាមភូមិ បានហេតុ ៦ មានលោភហេតុជាដើម

រូបភូមិ បានហេតុ ៣ មានអលោភហេតុជាដើម
អរូបភូមិ បានហេតុ ៣ មានអលោភហេតុជាដើម
លោកុត្តរភូមិ បានហេតុ ៣ មានអលោភហេតុជាដើម

៥-ដោយបុគ្គលផ្សេង ៗ គឺ

បុថុជ្ជន បានហេតុ ៦ មានលោភហេតុជាដើម
ព្រះសោតាបន្ន បានហេតុ ៦ មានលោភហេតុជាដើម
ព្រះសកទាគាមី បានហេតុ ៦ មានលោភហេតុជាដើម
ព្រះអនាគាមី បានហេតុ ៥ មានលោភហេតុជាដើម
(វៀរទោសហេតុ)
ព្រះអរហន្ត បានហេតុ ៣ មានអលោភៈ អទោសៈ និង
អមោហហេតុ ។

## សម្តែងចេតសិកដោយហេតុ

អាចារ្យខ្លះសម្តែងចេតសិកដោយហេតុ ជា ២ ន័យ គឺ -

១-អគហិតគហនន័យ គឺ ន័យដែលរាប់ហើយ មិនរាប់ទៀត

២-គហិតគហនន័យ គឺ ន័យដែលរាប់ហើយ រាប់ទៀត ។

## ការសង្គ្រោះចេតសិក ដោយហេតុ មាន៥ ន័យ គឺ

១-ចេតសិកដែលមានហេតុតែមួយ មាន ៣ គឺ -

វិចិកិច្ឆាចេតសិក មានមោហហេតុ (មោហៈជាហេតុ)

លោភចេតសិក មានមោហហេតុ (មោហៈជាហេតុ)

ទោសចេតសិក មានមោហហេតុ (មោហៈជាហេតុ)

* ចំណែកចេតសិកដែលនៅសល់ ៤៩ មិនមែនមានហេតុតែមួយទេ, រួមជាចេតសិក ៥២ ។

២-ចេតសិកដែលមានហេតុ ២ មាន ៩ គឺ -

មោហៈ មានលោភហេតុ និងទោសហេតុ

ទិដ្ឋិ មានះ មានលោភហេតុ និងមោហហេតុ

ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ មានទោសហេតុ និងមោហហេតុ

អលោភៈ មានអទោសហេតុ និងអមោហហេតុ

អទោសៈ មានអលោភហេតុ និងអមោហហេតុ

អមោហៈ មានអលោភហេតុ និងអទោសហេតុ

* ចំណែកចេតសិកដែលនៅសល់ ៤៣ មិនមែនមានហេតុ ២ ទេ, រួមជាចេតសិក ៥២ ។

៣-ចេតសិកដែលមានហេតុ ៣ មាន ២៧ គឺ

អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ ថីទុកៈ (ទាំង ៥ នេះ) មានលោភៈ ទោសៈ មោហហេតុកើតរួមផង

សោភណចេតសិក ២២ (វៀរអលោភៈ អទោសៈ អមោហៈ) មានអលោភៈ អទោសៈ អមោហហេតុ កើតរួមផង ។

* ចេតសិកដែលនៅសល់ ២៥ មិនមែនមានហេតុ ៣ ទេ រួមជាចេតសិក ៥២ ។

៤- ចេតសិកដែលមានហេតុ ៥ មាន ១ គឺ បីតិចេតសិក (វៀរទោសហេតុ)

* ចេតសិក ៥១ មិនមែនមានហេតុ ៥ ទេ ។

៥- ចេតសិកដែលមានហេតុ ៦ មាន ១២ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ)

* ចេតសិក ៤០ មិនមែនមានហេតុ ៦ កើតរួមផងទេ ។

## ការរាប់ហេតុក្នុងចិត្តប្បាទដោយពិស្តារ

ការរាប់ហេតុដោយជាតិទាំង ៤ គឺ ជាតិដែលជាអកុសល ១ ជាតិដែលជាកុសល ១ ជាតិដែលជាវិបាក ១ ជាតិដែលជាកិរិយា ១ រួម ៤ ជាតិ នឹងបានហេតុរួម ២៨៣ ហេតុ ដូច្នេះ គឺ ៈ

១-អកុសលហេតុ មាន ២២ ហេតុ គឺ មានលោភហេតុ ៨ (ក្នុងលោភមូលចិត្ត៨) មានទោសហេតុ២ (ក្នុងទោសមូលចិត្ត២) មានមោហហេតុ១២ (ក្នុងអកុសលចិត្ត ១២) ។

២-កុសលហេតុ មាន ១០៧ ហេតុ គឺ មានអលោភហេតុ ៣៧ (ក្នុងមហាកុសលចិត្ត៨ មហគ្គតចិត្ត៩ លោកុត្តរមគ្គចិត្ត២០), មានអទោសហេតុ ៣៧ (ក្នុងមហាកុសលចិត្ត៨ មហគ្គតចិត្ត៩ លោកុត្តរមគ្គចិត្ត២០) មានអមោហហេតុ ៣៣ (ក្នុងមហាកុសលញាណសម្បយុត្ត ៤ មហគ្គតចិត្ត ៩ លោកុត្តរចិត្ត ២០) ។

៣-វិបាកហេតុ មាន១០៧ ហេតុ គឺ មានអលោភហេតុ ៣៧, មានអទោសហេតុ ៣៧, មានអមោហហេតុ ៣៣ ។

៤-កិរិយាហេតុ មាន ៤៧ ហេតុ គឺ -

-មានអលោភហេតុ ១៧ (ក្នុងមហាកិរិយាចិត្ត៨ មហគ្គតកិរិយាចិត្ត ៩)

-មានអទោសហេតុ ១៧ (ក្នុងមហាកិរិយាចិត្ត៨ មហគ្គតកិរិយាចិត្ត ៩)

-មានអមោហហេតុ ១៣ (ក្នុងមហាកិរិយាញាណសម្បយុត្តចិត្ត៤ មហគ្គតកិរិយាចិត្ត៩)

<u>រួមទាំងអស់</u> គឺ អកុសលហេតុ ២២ កុសលហេតុ ១០៧ វិបាកហេតុ ១០៧ កិរិយាហេតុ ៤៧ = ២៨៣ ហេតុ ។

## សរុបការរាប់ចិត្ត ៨៩

ដោយមានហេតុ និង មិនមានហេតុ ៤ ន័យ

១-ចិត្តមិនមានហេតុ មាន ១៨

២-ចិត្តមានហេតុ ១ មាន ២

៣-ចិត្តមានហេតុ ២ មាន ២២

៤-ចិត្តមានហេតុ ៣ មាន ៤៧

សរុបការរាប់ចេតសិក ៥២ ដោយមានហេតុ រួម ៥ ន័យ

១-ចេតសិកមានហេតុ ១ មាន ៣

២-ចេតសិកមានហេតុ ២ មាន ៩

៣-ចេតសិកមានហេតុ ៣ មាន ២៧

៤-ចេតសិកមានហេតុ ៥ មាន ១

៥-ចេតសិកមានហេតុ ៦ មាន ១២

ចប់ ហេតុសង្គហៈ

# ៣.កិច្ចសង្គហៈ

## សង្គហគាថា

៧. បដិសន្ធាទយោ នាម  កិច្ចភេទេន ចុទ្ទស
ទសធា ឋានភេទេន  ចិត្តុប្បាទា បកាសិតា ។

ចិត្តុប្បាទទាំងឡាយ ឈ្មោះថា បដិសន្ធិជាដើម ព្រះមានព្រះភាគ ទ្រង់ប្រកាសទុក ១៤ យ៉ាង ដែលផ្សេងគ្នាដោយកិច្ច និង ១០ យ៉ាង ដែលផ្សេងគ្នាដោយឋាន ។

៨. អដ្ឋសដ្ឋី តថា ទ្វេ ច  នវដ្ឋ ទ្វេ យថាក្កមំ
ឯកទ្វិតិចតុបញ្ច  កិច្ចដ្ឋានានិ និទ្ទិសេ ។

បណ្ឌិតគប្បីសម្ដែងនូវចិត្ត ដែលមានកិច្ច ១ និងឋាន ១. មានកិច្ច២ និងឋាន២. មានកិច្ច៣ និង ឋាន៣. កិច្ច៤ និងឋាន៤. កិច្ច ៥ និងឋាន៥. គឺ ចិត្ត៦៨, ២, ៩, ៨, និងចិត្ត ២ តាមលំដាប់ ។

# អធិប្បាយកិច្ចសង្គហៈ

ការរួបរួមចិត្តនិងចេតសិក ដោយប្រភេទនៃកិច្ច ឈ្មោះថា កិច្ចសង្គហៈ ។ ក្នុងសង្គហគាថានេះ សម្ដែងកិច្ចរបស់ចិត្ត (ចិត្តុប្បាទ) ទុក ១៤ កិច្ច និងសម្ដែងឋានរបស់ចិត្ត ១០ យ៉ាង ។

បណ្ឌិតគប្បីជ្រាបកិច្ច និងឋានរបស់ចិត្ត តទៅ ៖

<u>អត្ថយោជនា ទុតិយភាគ</u>

**កិច្ច** មានវចនត្ថៈថា **កត្តព្វានីតិ កិច្ចានិ** ប្រែថា កិច្ចពួកណា មានបដិសន្ធិជាដើមដែលចិត្តគប្បីធ្វើ ព្រោះហេតុនោះ កិច្ចពួកនោះ ឈ្មោះថា ដែលចិត្តគប្បីធ្វើ ។

ពាក្យថា បដិសន្ធិជាដើមនេះ ជាឈ្មោះរបស់កិច្ចខ្លះ ជាឈ្មោះរបស់ចិត្តខ្លះ ។

ពាក្យថា កិច្ច ជាឈ្មោះរបស់ចេតនា អ្នកធ្វើ ក៏មាន,

<u>អត្ថយោជនា បឋមភាគ</u>

កិច្ច មានវចនត្ថៈថា **កត្តព្វន្តិ កិច្ចំ** ប្រែថា ការងារណា ដែលគេគប្បីធ្វើ ដោយចេតនា ព្រោះហេតុនោះ ការងារនោះ ឈ្មោះថា កិច្ច (ការធ្វើការងារដោយចេតនា) ។

<u>អត្ថយោជនាទុតិយភាគ</u>

ឋាន មានវចនត្ថៈថា **តិដ្ឋន្តិ ឯត្ថាតិ = ឋានំ** ប្រែថា បដិសន្ធិជាដើម តាំងនៅក្នុងឱកាសនេះ ព្រោះហេតុនោះ ឱកាសនេះ ឈ្មោះថា ឋាន គឺ ទីវាងចន្លោះ នៃបដិសន្ធិជាដើម ។

**កិច្ចរបស់ចិត្ត មាន ១៤ យ៉ាង**

១-បដិសន្ធិកិច្ច ចិត្តដែលធ្វើកិច្ចបន្តភពថ្មី

២-ភវង្គកិច្ច ចិត្តដែលធ្វើកិច្ចជាអង្គនៃភព

៣-អាវជ្ជនកិច្ច ចិត្តដែលធ្វើកិច្ចរាវរកនូវអារម្មណ៍

៤-ទស្សនកិច្ច ចិត្តដែលធ្វើកិច្ចមើល ឃើញនូវពណ៌

៥-សវនកិច្ច ចិត្តដែលធ្វើកិច្ចស្តាប់ ឮនូវសំឡេង

៦-ឃាយនកិច្ច ចិត្តដែលធ្វើកិច្ចហិត ធុំនូវក្លិន
៧-សាយនកិច្ច ចិត្តដែលធ្វើកិច្ចភ្លក់ ស្រូបនូវរស
៨-ផុស្សនកិច្ច ចិត្តដែលធ្វើកិច្ចប៉ះពាល់នូវសម្ផស្ស
៩-សម្បដិច្ឆន្នកិច្ច ចិត្តដែលធ្វើកិច្ចទទួលនូវបញ្ចារម្មណ៍
១០-សន្តីរណកិច្ច ចិត្តដែលធ្វើកិច្ចពិចារណានូវបញ្ចារម្មណ៍
១១-វោដ្ឋព្វនកិច្ច ចិត្តដែលធ្វើកិច្ចកាត់ក្តីអារម្មណ៍
១២-ជវនកិច្ច ចិត្តដែលធ្វើកិច្ចសេពសោយអារម្មណ៍
១៣-តទាលម្ពនកិច្ច ចិត្តដែលធ្វើកិច្ចទទួលអារម្មណ៍តពីជវន
១៤-ចុតិកិច្ច ចិត្តដែលធ្វើកិច្ចឃ្លាតចាកភពបច្ចុប្បន្ន

## អធិប្បាយចិត្តធ្វើកិច្ច ១៤ យ៉ាង

១-ចិត្តដែលធ្វើកិច្ចបដិសន្ធិបន្តភពថ្មី (គឺ តពីអតីតភពមក) មាន ១៩ គឺ ឧបេក្ខាសន្តីរណចិត្ត[១] ២, មហាវិបាកចិត្ត ៨, មហគ្គតវិបាកចិត្ត ៩

---

១. គឺ អហេតុកវិបាកមនោវិញ្ញាណធាតុ សរសេរថា សន្តីរណចិត្ត ដើម្បីឱ្យខ្លី

២-ចិត្តដែលធ្វើកិច្ចរក្សាភព (ការកើត) របស់ខ្លួនឱ្យប្រព្រឹត្តទៅមិនឱ្យដាច់ដោយយ៉ាងដទៃ ដូចបដិសន្ធិមកដោយចិត្តណា ក៏ឱ្យចិត្តនោះ ប្រព្រឹត្តទៅរហូតដល់អស់ជីវិត ក្នុងភពមួយ មាន ១៩ ដូចគ្នា និងបដិសន្ធិចិត្តនោះឯង ។

៣-ចិត្តដែលធ្វើកិច្ចរាវរកអារម្មណ៍ ដែលមកកាន់គន្លងទ្វារ មាន២ គឺ បញ្ចទ្វារាវជ្ជនចិត្ត ១ ធ្វើកិច្ចរាវរកអារម្មណ៍ដែលមកកាន់គន្លងបញ្ចទ្វារ, មនោទ្វារាវជ្ជនចិត្ត១ ធ្វើកិច្ចរាវរកអារម្មណ៍ដែលមកកាន់គន្លងមនោទ្វារ

៤-ចិត្តដែលធ្វើកិច្ចឃើញរូបារម្មណ៍ មាន២ គឺចក្ខុវិញ្ញាណ២

៥-ចិត្តដែលធ្វើកិច្ចបានឮសំឡេង មាន២ គឺសោតវិញ្ញាណ២

៦-ចិត្តដែលធ្វើកិច្ចស្រូបក្លិន មាន២ គឺ ឃានវិញ្ញាណ២

៧-ចិត្តដែលធ្វើកិច្ចភ្លក់រស មាន២ គឺ ជិវ្ហាវិញ្ញាណ២

៨-ចិត្តដែលធ្វើកិច្ចប៉ះខ្ទប់សម្ផស្ស មាន២ គឺកាយវិញ្ញាណ២

៩-ចិត្តដែលធ្វើកិច្ចទទួលបញ្ចារម្មណ៍ មាន ២ គឺ

វិបាកមនោធាតុ ២

១០-ចិត្តដែលធ្វើកិច្ចពិចារណាបញ្ចារម្មណ៍មាន ៣ គឺ ឧបេក្ខាសន្តីរណចិត្ត ២ សោមនស្សសន្តីរណចិត្ត ១

១១-ចិត្តដែលធ្វើកិច្ចកាត់ក្តីអារម្មណ៍ មាន ១ គឺ មនោទ្វារាវជ្ជនចិត្ត ១

១២-ចិត្តដែលធ្វើកិច្ចសេពសោយអារម្មណ៍ មាន ៥៥ គឺ អកុសលចិត្ត១២ ហសិតុប្បាទចិត្ត១ មហាកុសលចិត្ត៨ មហាកិរិយាចិត្ត៨ មហគ្គតកុសលចិត្ត៩ មហគ្គតកិរិយាចិត្ត៩ លោកុត្តរចិត្ត៨

១៣-ចិត្តដែលធ្វើកិច្ចទទួលអារម្មណ៍តពីជវនៈមាន១១ គឺ សន្តីរណចិត្ត ៣ មហាវិបាកចិត្ត ៨

១៤-ចិត្តដែលធ្វើកិច្ចឃ្លាតចាកភព មាន ១៩ គឺ ឧបេក្ខាសន្តីរណចិត្ត២ មហាវិបាកចិត្ត៨ មហគ្គតវិបាកចិត្ត៩

## កិច្ចដោយពិស្តារមាន ២ ន័យ

១-ចិត្តដែលធ្វើកិច្ច ដោយពិស្តារ មាន ៥ ន័យ

២-ចេតសិកដែលធ្វើកិច្ច ដោយពិស្តារ មាន ៧ ន័យ

## ចិត្តធ្វើកិច្ចដោយពិស្តារ ៥ ន័យ

ន័យទី ១ ចិត្តធ្វើកិច្ច ១ យ៉ាង មាន ៦៨ ឬ១០០ គឺ បញ្ចទ្វារាវជ្ជនចិត្ត១ ធ្វើអាវជ្ជនកិច្ច, ចក្ខុវិញ្ញាណ២ ធ្វើទស្សនកិច្ច សោតវិញ្ញាណ២ ធ្វើសវនកិច្ច, ឃានវិញ្ញាណ២ ធ្វើឃាយនកិច្ច ជិវ្ហាវិញ្ញាណ២ ធ្វើសាយនកិច្ច, កាយវិញ្ញាណ២ ធ្វើផុស្សនកិច្ច វិបាកមនោធាតុ២ ធ្វើសម្បដិច្ឆន្នកិច្ច, ហសិតុប្បាទចិត្ត១ អកុសលចិត្ត១២ មហាកុសលចិត្ត៨ មហាកិរិយាចិត្ត៨ មហគ្គត កុសលចិត្ត៩ មហគ្គតកិរិយាចិត្ត៩ លោកុត្តរចិត្ត ៨ឬ៤០ ធ្វើ ជវនកិច្ច ។

* ចិត្តដែលមិនធ្វើកិច្ច១ មាន២១ រួម៨៩ ឬ១២១ ។

<u>**ន័យទី ២**</u> ចិត្តធ្វើកិច្ច ២ យ៉ាង មាន ២ គឺ

សោមនស្សសន្តីរណចិត្ត១ ធ្វើសន្តីរណកិច្ច និង តទាលម្ពនកិច្ច

មនោទ្វារាវជ្ជនចិត្ត ១ ធ្វើវោដ្ឋពនកិច្ច និងអាវជ្ជនកិច្ច

* ចិត្តដែលមិនធ្វើកិច្ច ២ យ៉ាង មាន ៨៧

<u>**ន័យទី ៣**</u> ចិត្តធ្វើកិច្ច ៣ យ៉ាង មាន ៩ គឺ

មហគ្គតវិបាកចិត្ត ៩ ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច និង ចុតិកិច្ច ។

* ចិត្តដែលមិនធ្វើកិច្ច ៣ យ៉ាង មាន ៨០

<u>**ន័យទី ៤**</u> ចិត្តធ្វើកិច្ច ៤ យ៉ាង មាន ៨ គឺ

មហាវិបាកចិត្ត ៨ ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច តទាលម្ពនកិច្ច និង ចុតិកិច្ច ។

* ចិត្តដែលនៅសល់ ៨១ មិនធ្វើកិច្ច ៤ យ៉ាងទេ

<u>**ន័យទី ៥**</u> ចិត្តធ្វើកិច្ច ៥ យ៉ាង មាន ២ គឺ

ឧបេក្ខាសន្តីរណចិត្ត ២ ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច សន្តីរណកិច្ច តទាលម្ពនកិច្ច និង ចុតិកិច្ច ។

* ចិត្តដែលនៅសល់ ៨៧ មិនធ្វើកិច្ច ៥ យ៉ាងទេ

## ចេតសិកធ្វើកិច្ច ដោយពិស្តារ ៧ ន័យ

<u>ន័យទី ១</u> ចេតសិកធ្វើកិច្ច ១ យ៉ាង មាន ១៧ គឺ

អកុសលចេតសិក ១៤ ធ្វើជវនកិច្ច

វិរតិចេតសិក ៣ ដែលនៅក្នុងមហាកុសលចិត្ត ៨ លោកុត្តរ ៨ ឬ ៤០ ធ្វើជវនកិច្ច

* ចេតសិកដែលនៅសល់ ៣៥ មិនធ្វើកិច្ច ១ យ៉ាងទេ

**<u>ន័យទី ២</u>** ចេតសិកធ្វើកិច្ច ៤ យ៉ាង មាន ២ គឺ

-អប្បមញ្ញាចេតសិក ២ ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ជវនកិច្ច និង ចុតិកិច្ច ។

\+ អប្បមញ្ញាទាំង ២ នេះ បើកើតក្នុងមហាកុសលចិត្ត ៨, មហាកិរិយាចិត្ត ៨ រូបាវចរកុសលចិត្ត ៤ រូបាវចរកិរិយាចិត្ត ៤ ធ្វើជវនកិច្ចតែម្យ៉ាង ។

\+ បើកើតរួមនឹងរូបាវចរវិបាកចិត្ត ៤ ធ្វើកិច្ច ៣ យ៉ាង គឺ បដិសន្ធិកិច្ច ភវង្គកិច្ច និងចុតិកិច្ច ។

* ចេតសិកដែលនៅសល់ ៥០ មិនធ្វើកិច្ច៤ យ៉ាងទេ

<u>**ន័យទី ៣**</u> ចេតសិកធ្វើកិច្ច ៥ យ៉ាង មាន ២១ គឺ ឆន្ទចេតសិក ១ សោភណសាធារណចេតសិក ១៩ បញ្ញាចេតសិក ១ ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ជវនកិច្ច តទាលម្ពនកិច្ច និងចុតិកិច្ច

* ចេតសិកដែលនៅសល់៣១ មិនធ្វើកិច្ច ៥យ៉ាងទេ ។

<u>**ន័យទី ៤**</u> ចេតសិកធ្វើកិច្ច ៦ យ៉ាង មាន ១ គឺ បីតិចេតសិក ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច សន្តីរណកិច្ច ជវនកិច្ច តទាលម្ពនកិច្ច និងចុតិកិច្ច ។

\+ បីតិចេតសិកនេះ កាលកើតរួមនឹងសោមនស្ស ក្នុងអកុសលចិត្ត កុសលចិត្ត កិរិយាចិត្ត និងផលចិត្ត រមែងធ្វើជវនកិច្ចតែម្យ៉ាង

\+ កាលកើតរួមនឹងសោមនស្សសន្តីរណចិត្ត ក៏ធ្វើសន្តីរណកិច្ច និងតទាលម្ពនកិច្ច

+ កាលកើតរួមនឹងសោមនស្សសហគតចិត្ត ដែលជារូបាវចរវិបាកចិត្ត ៣ ក៏ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច និងចុតិកិច្ច

+ កាលកើតរួមនឹងសោមនស្សសហគតចិត្តដែលជាមហាវិបាក ៤ ក៏ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច តទាលម្ពនកិច្ច និងចុតិកិច្ច

* ចេតសិកនៅសល់ ៥១ មិនធ្វើកិច្ច ៦ យ៉ាងទេ ។

<u>**ន័យទី ៥**</u> ចេតសិកធ្វើកិច្ច ៧ យ៉ាង មាន ១ គឺ វីរិយចេតសិក ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច អាវជ្ជនកិច្ច វោដ្ឋព្វនកិច្ច ជវនកិច្ច តទាលម្ពនកិច្ច និងចុតិកិច្ច ។

+ វីរិយចេតសិកនេះ កាលកើតក្នុងអកុសលចិត្ត កុសលចិត្ត កិរិយាចិត្ត ផលចិត្ត រមែងធ្វើជវនកិច្ច

+ កាលកើតក្នុងវិបាកមនោធាតុ ក៏ធ្វើសម្បដិច្ឆន្នកិច្ច

+ កាលកើតក្នុងមនោទ្វារាវជ្ជនចិត្ត ក៏ធ្វើអាវជ្ជនកិច្ច និងវោដ្ឋព្វនកិច្ច

+ កាលកើតក្នុងមហាវិបាកចិត្ត ក៏ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច តទាលម្ពនកិច្ច និងចុតិកិច្ច

+ កាលកើតក្នុងមហគ្គតវិបាកចិត្តក៏ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច និង ចុតិកិច្ច

* ចេតសិកនៅសល់ ៥១ មិនធ្វើកិច្ច ៧ យ៉ាងទេ ។

<u>**ន័យទី ៦**</u> ចេតសិកធ្វើកិច្ច ៩ យ៉ាង មាន ៣ គឺ វិតក្កចេតសិក ១ វិចារចេតសិក ១ អធិមោក្ខចេតសិក ១ (ទាំង ៣ នេះ) រមែងធ្វើកិច្ច ៩ យ៉ាង គឺ បដិសន្ធិកិច្ច ភវង្គកិច្ច អាវជ្ជនកិច្ច សម្បដិច្ឆន្នកិច្ច សន្តីរណកិច្ច វោដ្ឋព្វនកិច្ច ជវនកិច្ច តទាលម្ពនកិច្ច និង ចុតិកិច្ច ។

+ ក៏ចេតសិកទាំង ៣ នេះ កាលកើតក្នុងអកុសលចិត្ត កុសលចិត្ត កិរិយាចិត្ត ផលចិត្ត ក៏ធ្វើជវនកិច្ច

+ កាលកើតក្នុងមនោទ្វារាវជ្ជនចិត្ត ក៏ធ្វើអាវជ្ជនកិច្ច និងវោដ្ឋព្វនកិច្ចតាមបញ្ចទ្វារ ។

+ កាលកើតក្នុងសន្តីរណចិត្ត ក៏ធ្វើសន្តីរណកិច្ច

+ កាលកើតក្នុងមហាវិបាកចិត្ត ក៏ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច តទាលម្ពនកិច្ច និងចុតិកិច្ច ។

+ កាលកើតក្នុងមហគ្គតវិបាកចិត្ត ក៏ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច និងចុតិកិច្ច ។

* ចេតសិកនៅសល់ ៤៩ មិនធ្វើកិច្ច ៩ យ៉ាងទេ ។

**<u>ន័យទី ៧</u>** ចេតសិកធ្វើកិច្ច ១៤ យ៉ាង មាន ៧ គឺ សព្វចិត្តសាធារណចិត្ត ៧

* ចេតសិកដែលនៅសល់៤៥ មិនធ្វើកិច្ច១៤ យ៉ាងទេ ។

## សរុបចិត្តធ្វើកិច្ច ៥ ន័យ

១-ចិត្តធ្វើកិច្ច ១ យ៉ាង មាន ៦៨ ឬ១០០

២-ចិត្តធ្វើកិច្ច ២ យ៉ាង មាន ២

៣-ចិត្តធ្វើកិច្ច ៣ យ៉ាង មាន ៩

៤-ចិត្តធ្វើកិច្ច ៤ យ៉ាង មាន៨

៥-ចិត្តធ្វើកិច្ច ៥ យ៉ាង មាន២

## សរុបចេតសិកធ្វើកិច្ច ៧ ន័យ

១-ចេតសិកធ្វើកិច្ច ១ យ៉ាង មាន ១៧

២-ចេតសិកធ្វើកិច្ច ៤ យ៉ាង មាន ២

៣-ចេតសិកធ្វើកិច្ច ៥ យ៉ាង មាន ២១

៤-ចេតសិកធ្វើកិច្ច ៦ យ៉ាង មាន ១

៥-ចេតសិកធ្វើកិច្ច ៧ យ៉ាង មាន ១

៦-ចេតសិកធ្វើកិច្ច ៩ យ៉ាង មាន ៣

៧-ចេតសិកធ្វើកិច្ច ១៤ យ៉ាង មាន ៧

## ឋាននៃចិត្ត មាន ១០ ឋាន

កិច្ចរបស់ចិត្ត តាមដែលពោលទុកហើយនោះ នឹងប្រាកដបានល្អ ក៏ត្រូវអាស្រ័យឋាន (ទីតាំង) នៃចិត្តប្បាទ ដើម្បីឱ្យជ្រាបថា កិច្ចរបស់ចិត្តនោះ តាំងនៅឋានណា ដូច្នេះ ។

**គប្បីជ្រាបឋានរបស់ចិត្ត ដូចតទៅនេះ ៖**

១-បដិសន្ធិស្ថាន បានដល់ ឋាននៃចិត្តដែលធ្វើបដិសន្ធិកិច្ច
២-ភវង្គស្ថាន បានដល់ ឋាននៃចិត្តដែលធ្វើភវង្គកិច្ច
៣-អាវជ្ជនស្ថាន បានដល់ ឋាននៃចិត្តដែលធ្វើអាវជ្ជនកិច្ច
៤-បញ្ចវិញ្ញាណស្ថាន បានដល់ ឋាននៃចិត្តដែលធ្វើទស្សនកិច្ច សវនកិច្ច ឃាយនកិច្ច សាយនកិច្ច ផុស្សនកិច្ច
៥-សម្បដិច្ឆន្នស្ថាន បានដល់ ឋាននៃចិត្តដែលធ្វើសម្បដិច្ឆន្នកិច្ច
៦-សន្តីរណស្ថាន បានដល់ ឋាននៃចិត្តដែលធ្វើសន្តីរណកិច្ច
៧-វោដ្ឋព្វនស្ថាន បានដល់ ឋាននៃចិត្តដែលធ្វើវោដ្ឋព្វនកិច្ច
៨-ជវនស្ថាន បានដល់ ឋាននៃចិត្តដែលធ្វើជវនកិច្ច
៩-តទាលម្ពនស្ថាន បានដល់ ឋាននៃចិត្តដែលធ្វើតទាលម្ពនកិច្ច
១០-ចុតិស្ថាន បានដល់ ឋាននៃចិត្តដែលធ្វើចុតិកិច្ច ។

## អធិប្បាយឋាន ១០ យ៉ាង

១-បដិសន្ធិស្ថាន មាន ១ ស្ថាន គឺ

ត្រង់ចន្លោះចុតិ និងភវង្គ

២-ភវង្គស្ថាន មាន ៦ ស្ថាន គឺ -

១-ត្រង់ចន្លោះបដិសន្ធិ និងអាវជ្ជនៈ

២-ត្រង់ចន្លោះជវន និងអាវជ្ជនៈ

៣-ត្រង់ចន្លោះតទាលម្ពនៈ និងអាវជ្ជនៈ

៤-ត្រង់ចន្លោះវោដ្ឋព្វនៈ និងអាវជ្ជនៈ

៥-ត្រង់ចន្លោះជវន និងចុតិ

៦-ត្រង់ចន្លោះតទាលម្ពនៈ និងចុតិ

៣-អាវជ្ជនស្ថាន មាន ២ ស្ថាន គឺ

១-ត្រង់ចន្លោះភវង្គចិត្ត និងបញ្ចវិញ្ញាណ

២-ត្រង់ចន្លោះភវង្គចិត្ត និងជវនចិត្ត

៤-បញ្ចវិញ្ញាណស្ថាន មាន ១ ស្ថាន គឺ

ត្រង់ចន្លោះបញ្ចទ្វារាវជ្ជនចិត្ត និងវិបាកមនោធាតុ

៥-សម្បដិច្ឆន្នស្ថាន មាន ១ ស្ថាន គឺ

ត្រង់ចន្លោះបញ្ចវិញ្ញាណ និងសន្តីរណចិត្ត

៦-សន្តីរណស្ថាន មាន ១ ស្ថាន គឺ

ត្រង់ចន្លោះវិបាកមនោធាតុ និងវោដ្ឋព្វនចិត្ត

៧-វោដ្ឋព្វនស្ថាន មាន ២ ស្ថាន គឺ -

១-ត្រង់ចន្លោះសន្តីរណចិត្ត និងជវនចិត្ត

២-ត្រង់ចន្លោះសន្តីរណចិត្ត និងភវង្គចិត្ត

៨-ជវនស្ថាន មាន ៦ ស្ថាន គឺ -

១-ត្រង់ចន្លោះវោដ្ឋព្វនចិត្ត និងតទាលម្ពនចិត្ត

២-ត្រង់ចន្លោះវោដ្ឋព្វនចិត្ត និងភវង្គចិត្ត

៣-ត្រង់ចន្លោះវោដ្ឋព្វនចិត្ត និងចុតិចិត្ត

៤-ត្រង់ចន្លោះមនោទ្វារាវជ្ជនចិត្ត និងតទាលម្ពនចិត្ត

៥-ត្រង់ចន្លោះមនោទ្វារាវជ្ជនចិត្ត និងភវង្គចិត្ត

៦-ត្រង់ចន្លោះមនោទ្វារាវជ្ជនចិត្ត និងចុតិចិត្ត

៩-តទាលម្ពនស្ថាន មាន ២ ស្ថាន គឺ -

១-ត្រង់ចន្លោះជវនចិត្ត និងភវង្គចិត្ត

២-ត្រង់ចន្លោះជវនចិត្ត និងចុតិចិត្ត

១០-ចុតិស្ថាន មាន ៣ ស្ថាន គឺ

១-ត្រង់ចន្លោះជវនចិត្ត និងបដិសន្ធិចិត្ត

២-ត្រង់ចន្លោះភវង្គចិត្ត និងបដិសន្ធិចិត្ត

៣-ត្រង់ចន្លោះតទាលម្ពនចិត្ត និងបដិសន្ធិចិត្ត

ឋាននៃចិត្តប្បាទ ១០ នេះ កាលសម្តែងដោយពិស្តារ ដែលរាប់ចំនួន តាមវិថីចិត្តហើយ រមែងបាន ២៥ ឋាន ។

**ចប់ កិច្ចសង្គហៈ**

## ៤-ទ្វារសង្គហៈ

ការរួបរួមចិត្ត ចេតសិក(ចិត្តុប្បាទ) ដោយប្រភេទនៃទ្វារ ឈ្មោះថា ទ្វារសង្គហៈ ។ ពាក្យថា **ទ្វារ** ប្រែថា ប្រកមានសន្ទុះ ឬទនាំង សម្រាប់បើកបិទ ចេញចូល ។ ពាក្យនេះ មានសេចក្ដី សំដៅទាំងបរមត្ថ និងបញ្ញត្តិ ។

**<u>ក្នុងអត្ថយោជនា</u>** សម្ដែងថា ៖

**ទ្វារ** មានវិចនត្ថៈថា **ទេ្វ ករោជា អវន្តិ ឯតស្មាតិ ទ្វារានិ** : ទ្វារទាំង ២ រមែងប្រព្រឹត្តទៅក្នុងទីនេះ ព្រោះហេតុនោះ ទីនេះ ទើបឈ្មោះថា ទ្វារ ។

### ទ្វារសង្គហៈ មាន ៦ យ៉ាង

១-ចក្ខុទ្វារ បានដល់ ចក្ខុប្រសាទរូប

២-សោតទ្វារ បានដល់ សោតប្រសាទរូប

៣-ឃានទ្វារ បានដល់ ឃានប្រសាទរូប

៤-ជិវ្ហាទ្វារ បានដល់ ជិវ្ហាប្រសាទរូប

៥-កាយទ្វារ បានដល់ កាយប្រសាទរូប

៦-មនោទ្វារ បានដល់ ភវង្គចិត្ត ១៩

## អធិប្បាយ ទ្វារសង្គហៈ

ការរួបរួមទ្វារទាំងឡាយ និងចិត្តដែលប្រព្រឹត្តទៅក្នុងទ្វារ ដោយអំណាចនៃការកំណត់ ឈ្មោះថា ទ្វារសង្គហៈ ។

ចក្ខុជាដើម ឈ្មោះថា ទ្វារ ព្រោះអត្ថថា ដូចជាទ្វារ ព្រោះភាពជាហេតុនៃការប្រព្រឹត្តិទៅរបស់អរូបធម៌ទាំងឡាយ មានអាវជ្ជនចិត្តជាដើម ។ ពាក្យថា ចក្ខុ បានដល់ ចក្ខុប្រសាទនោះឯង ។

**មនោទ្វារ** មានវិគ្រោះថា មនោនោះឯង ជាទ្វារនៃចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា មនោទ្វារ ។

ពាក្យថា ភវង្គៈ បានដល់ ភវង្គចិត្តក្នុងរវាងនៃអាវជ្ជនៈ ដោយហេតុនោះ ព្រះបូរាណាចារ្យ (ដីកា) ទើបពោលថា

"ចំណែកកភវង្គព្រមទាំងអាវជ្ជនៈ បណ្ឌិតទាំងឡាយហៅថា មនោទ្វារ( គឺ ភវង្គុបច្ឆេទ )" ដូច្នេះ ។

## សង្គហគាថា

៩. ឯកទ្វារិកចិត្តានិ បញ្ចទ្វារិកានិ ច
ឆទ្វារិកវិមុត្តានិ វិមុត្តានិ ច សព្វថា ។
១០. ឆត្តឹសតិ តថា តីណិ ឯកត្តឹស យថាក្កមំ
ទសធា នវធា ចេតិ បញ្ចធា បរិទីបយេ ។

បណ្ឌិតគប្បីសម្តែងចិត្ត ដែលប្រព្រឹត្តទៅក្នុងទ្វារតែមួយ ១. ចិត្តដែលប្រព្រឹត្តទៅក្នុងទ្វារទាំងប្រាំ ១. ចិត្តដែលប្រព្រឹត្តទៅក្នុងទ្វារទាំងប្រាំមួយ ១. ចិត្តដែលប្រព្រឹត្តទៅក្នុងទ្វារទាំងប្រាំមួយ គ្រាខ្លះផុតចាកពីទ្វារ ១ ចិត្តដែលផុតចាកពីទ្វារដោយគ្រប់ប្រការ ១. រួមជា ៥ គឺ ចិត្ត ៣៦. ៣. ៣១. ១០. និង ៩ តាមលំដាប់ ។

## អធិប្បាយ

**១-ឯកទ្វារិកចិត្ត** បានដល់ ចិត្តដែលអាស្រ័យទ្វារតែមួយកើតឡើង មាន៣៦ គឺ ទ្វិបញ្ចវិញ្ញាណ១០ អប្បនាជវនចិត្ត២៦

**២-បញ្ចទ្វារិកចិត្ត** បានដល់ ចិត្តដែលអាស្រ័យទ្វារ ៥ កើតឡើងមាន ៣ គឺ បញ្ចទ្វារាវជ្ជនចិត្ត១ វិបាកមនោធាតុ២

**៣-ឆទ្វារិកចិត្ត** បានដល់ ចិត្តដែលអាស្រ័យទ្វារ ៦ កើតឡើង មាន ៣១ គឺ សោមនស្សសន្តីរណចិត្ត ១ មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩

**៤-ឆទ្វារិកវិមុត្តចិត្ត** បានដល់ ចិត្តដែលអាស្រ័យទ្វារ ៦ កើតឡើង គ្រាខ្លះក៏មិនអាស្រ័យទ្វារ ៦ មាន ១០ គឺ ឧបេក្ខាសន្តីរណចិត្ត ២ មហាវិបាកចិត្ត ៨

ចិត្ត ១០ នេះ ខណៈធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច កិច្ចយ៉ាងណាមួយ មិនអាស្រ័យទ្វារ ៦ កើតឡើងទេ, គ្រាខ្លះធ្វើកិច្ចដទៃ ដូចឧបេក្ខាសន្តីរណចិត្ត ២ ធ្វើសន្តីរណកិច្ច ឬ

តទាលម្ពនកិច្ចក្តី មហាវិបាកចិត្ត ៨ ធ្វើតទាលម្ពនកិច្ចក្តី រមែងអាស្រ័យទ្វារ ៦ កើតឡើង ។

**៥-ឆទ្វារិកវិមុត្តចិត្ត សព្វថា** បានដល់ ចិត្តដែលផុតចាកទ្វារ ៦ ដោយប្រការទាំងពួង គឺ មហគ្គតវិបាកចិត្ត ៩

ចំណែកចិត្តដែលនៅសល់ ៨០ ទៀត ជាចិត្តដែលអាស្រ័យទ្វារកើតឡើង រួមជាចិត្ត ៨៩ ។

## ចែកចិត្តដោយពិស្តារ

១-__ឯកទ្វារិកចិត្ត__ (ចិត្តដែលកើតក្នុងទ្វារតែមួយ) ដែលប្រព្រឹត្តទៅក្នុងទ្វារ ៦,

ដោយឯកន្តៈ បានចិត្ត ៣៦ គឺ ទ្វិបញ្ចវិញ្ញាណ ១០ អប្បនាជវនចិត្ត ២៦

ដោយអនេកន្តៈ(មិនប្រាកដ)បានចិត្ត ៤៤ គឺ មនោធាតុ ៣ មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ តទាលម្ពនចិត្ត

១១ រួមជាចិត្ត ៨០

* ចិត្តដែលនៅសល់ ៩ (គឺ មហគ្គតវិបាកចិត្ត) មិនអាស្រ័យទ្វារកើត ។

ការសម្តែងឯកទ្វារិកចិត្តនេះ ជាការសម្តែងរួម ៦ ទ្វារ, កាលទឹងចែកជាទ្វារនីមួយ ៗ របស់ឯកទ្វារិកចិត្ត រមែងបានដូច្នេះ គឺ

**១-ចក្ខុទ្វារិកចិត្ត** (ចិត្តកើតតាមចក្ខុទ្វារ) មាន ៤៦ គឺ

ដោយឯកន្តៈ បានដល់ ចក្ខុវិញ្ញាណ ២

ដោយអនេកន្តៈ បានដល់ មនោធាតុ ៣ មនោទ្វារាវជ្ជនចិត្ត១ កាមជវនចិត្ត២៩ តទាលម្ពនចិត្ត១១

**២-សោតទ្វារិកចិត្ត** បានចិត្ត ៤៦ ដូចនឹងចក្ខុទ្វារិកចិត្ត

**៣-ឃានទ្វារិកចិត្ត** បានចិត្ត ៤៦ ដូចនឹងចក្ខុទ្វារិកចិត្ត

**៤-ជិវ្ហាទ្វារិកចិត្ត** បានចិត្ត ៤៦ ដូចនឹងចក្ខុទ្វារិកចិត្ត

**៥-កាយទ្វារិកចិត្ត** បានចិត្ត ៤៦ ដូចនឹងចក្ខុទ្វារិកចិត្ត

**៦-មនោទ្វារិកចិត្ត** (ចិត្តកើតតាមមនោទ្វារ) មាន៦៧ គឺ

ដោយឯកន្តៈ បានដល់ អប្បនាជវនចិត្ត ២៦

ដោយអនេកន្តៈ បានដល់ មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ តទាលម្ពនចិត្ត ១១

**២-បញ្ចទ្វារិកចិត្ត** (ចិត្តកើតតាមបញ្ចទ្វារ)មាន ៤៤ គឺ -

ដោយឯកន្តៈ បានដល់ មនោធាតុ ៣

ដោយអនេកន្តៈ បានដល់ មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ តទាលម្ពនចិត្ត ១១

**៣-ឆទ្វារិកចិត្ត** (ចិត្តដែលកើតតាមទ្វារ ៦) មាន ៤១ គឺ -

ដោយឯកន្តៈ បានដល់ សោមនស្សសន្តីរណចិត្ត ១ មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩

ដោយអនេកន្តៈ បានដល់ ឧបេក្ខាសន្តីរណចិត្ត ២ មហាវិបាកចិត្ត ៨

**៤-ទ្វារវិមុត្តចិត្ត** (ចិត្តដែលផុតចាកទ្វារ) មាន ១៩ គឺ -

ដោយឯកន្តៈ បានដល់ មហគ្គតវិបាកចិត្ត ៩

ដោយអនេកន្តៈ បានដល់ ឧបេក្ខាសន្តីរណចិត្ត ២ មហាវិបាកចិត្ត ៨

ចំណែកចេតសិកដែលកើតតាមទ្វារផ្សេង ៗនោះ ជាប់ដោយចិត្ត កាលចិត្តកើតតាមទ្វារណា ចេតសិកក៏កើតតាមទ្វារនោះ, ចេតសិកខ្លះកើតចំពោះទីកន្លែង ប្រព្រឹត្តទៅក្នុងសត្តប្បញ្ញត្តិតែម្យ៉ាង ដូចអប្បមញ្ញាចេតសិក ២ កើតតាមមនោទ្វារតែម្យ៉ាង, អទោសៈ និងតត្រមជ្ឈត្តតា មានសត្តប្បញ្ញត្តិជាអារម្មណ៍ ក៏បាន មានបរមត្ថជាអារម្មណ៍ ក៏បាន ក៏ប្រព្រឹត្តទៅតាមទ្វាររបស់ចិត្តនោះឯង ។

មួយទៀត ចេតសិកដែលផុតចាកទ្វារ ក៏ប្រព្រឹត្តទៅដូចគ្នា នឹងចិត្ត, តែចំពោះអប្បមញ្ញា ២ បើកើតផុតចាកពីទ្វាររមែងកើតក្នុងអរូបាវចរវិបាកចិត្ត ៤ ប៉ុណ្ណោះ ។

**ចប់ ទ្វារសង្គហៈ**

# ៥-អារម្មណសង្គហៈ

ការរួបរួមចិត្ត និងចេតសិកទាំងឡាយ ដោយប្រភេទនៃអារម្មណ៍ទាំងឡាយ ឈ្មោះថា អារម្មណសង្គហៈ ។

ពាក្យថា អារម្មណ៍ សំដៅដល់ វត្ថុជាទីតោងរបស់ចិត្ត និងចេតសិក ឬវត្ថុជាទីត្រេកអររបស់ចិត្ត និងចេតសិក ដូចឈើច្រត់ដែលបុរសមានកម្លាំងខ្សោយកាន់ទុក ឬ ដូចសួនផ្កាឈើជាទីត្រេកអររបស់មនុស្សទាំងឡាយ ។

លោកសម្ដែងវិគ្រោះទុក ២ ន័យ គឺ -

<u>ន័យទី ១</u> មានវិគ្រោះថា **អាលម្ពិយតីតិ = អាលម្ពនំ** ប្រែថា រូប(ជាដើមណា) ដែលចិត្ត និងចេតសិកទាំងឡាយតោងទុក ព្រោះហេតុនោះ រូប(ជាដើម)នោះ ទើបឈ្មោះថា អាលម្ពនៈ (បានអារម្មណ៍ទាំង ៦) ។

<u>ន័យទី ២</u> មានវិគ្រោះថា **តានិ វា អាគន្ត្វា ឯត្ថ រមន្តីតិ = អារម្មណំ** ប្រែថា ចិត្ត និងចេតសិកទាំងនោះ រមែង

ត្រេកអរក្នុងរូប(ជាដើម)នោះ ព្រោះហេតុនោះ រូប(ជាដើម)នោះ ទើបឈ្មោះថា អារម្មណ៍ (បានអារម្មណ៍ ៦) ។

**អារម្មណ៍មាន ៦ យ៉ាង**

| | |
|---|---|
| ១-រូបារម្មណ៍ | បានដល់ ពណ៌ផ្សេង ៗ |
| ២-សទ្ទារម្មណ៍ | បានដល់ សំឡេងផ្សេង ៗ |
| ៣-គន្ធារម្មណ៍ | បានដល់ ក្លិនផ្សេង ៗ |
| ៤-រសារម្មណ៍ | បានដល់ រសផ្សេង ៗ |
| ៥-ផោដ្ឋព្វារម្មណ៍ | បានដល់ ក្តៅ ត្រជាក់ ទន់ រឹង តឹង ញ័រ |
| ៦-ធម្មារម្មណ៍ | បានដល់ ចិត្ត ៨៩ ចេតសិក ៥២ រូប ២១ (វៀរទី ១-៥) និព្វាន បញ្ញត្តិផ្សេង ៗ ។ |

# អធិប្បាយអារម្មណ៍ ៦ មានរូបជាដើម

**១-រូបារម្មណ៍** ដែលឈ្មោះថា រូប ព្រោះអត្ថថា សម្តែងនូវអារម្មណ៍ដែលដល់នូវវិការៈនៃវណ្ណៈ គឺ ប្រកាសនូវភាវៈដែលប្រព្រឹត្តទៅក្នុងហទយៈ អារម្មណ៍ គឺ រូបនោះ ឈ្មោះថា រូបារម្មណ៍ ។

**២-សទ្ទារម្មណ៍** ដែលឈ្មោះថា សំឡេង ព្រោះអត្ថថា ដែលបុគ្គលនិយាយ គឺ ពោល, អារម្មណ៍ គឺ សំឡេងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា សទ្ទារម្មណ៍ ។

**៣-គន្ធារម្មណ៍** ដែលឈ្មោះថា គន្ធៈ(ក្លិន) ព្រោះអត្ថថា ប្រកាស គឺ សម្តែងកន្លែងរបស់ខ្លួន គឺ ជាអារម្មណ៍ ដូចធ្វើការបង្ហាញប្រាប់ថា មានវត្ថុ ឬរបស់នេះ នៅក្នុងទីនេះ(សូម្បីងឹត) ដូច្នេះ អារម្មណ៍ គឺ ក្លិននោះ ព្រោះហេតុនោះ ទើបឈ្មោះថា គន្ធារម្មណ៍ ។

**៤-រសារម្មណ៍** ដែលឈ្មោះថា រស ព្រោះអត្ថថា

ត្រេកអរ គឺ ជាទីពេញចិត្តរបស់សត្វទាំងឡាយ, អារម្មណ៍ គឺ រសនោះ ព្រោះហេតុនោះ ទើបឈ្មោះថា រសារម្មណ៍ ។

**៥_ផោដ្ឋព្វារម្មណ៍** ដែលឈ្មោះថា ផោដ្ឋព្វៈ ព្រោះអត្ថថា ដែលសត្វពាល់ត្រូវ ឬការពាល់ត្រូវ, អារម្មណ៍ គឺ ផោដ្ឋព្វៈនោះ ព្រោះហេតុនោះ ទើបឈ្មោះថា ផោដ្ឋព្វារម្មណ៍ ។

**៦_ធម្មារម្មណ៍** អារម្មណ៍ គឺ ធម៌ ឈ្មោះថា ធម្មារម្មណ៍ ។

បណ្តាអារម្មណ៍ ៦ នោះ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ហៅថា បញ្ចារម្មណ៍ ជារូបធម៌ ។ ចំណែកធម្មារម្មណ៍នោះ បានដល់ ធម៌ ៦ យ៉ាង ជាអារម្មណ៍ គឺ ចិត្ត ៨៩ ចេតសិក ៥២ ប្រសាទរូប ៥ សុខុមរូប ១៦ និព្វាន និងបញ្ញត្តិ ។

បណ្តាអារម្មណ៍ ៦ នេះ អារម្មណ៍ ៦ ដែលប្រព្រឹត្តទៅតាមធម្មតា ហៅថា សាមញ្ញារម្មណ៍, ចំណែកអារម្មណ៍ដែល

មានកម្លាំងច្រើន ជាហេតុឱ្យចិត្តចេតសិកជាប់នៅក្នុងអារម្មណ៍ គឺតោងទុកយ៉ាងណែនទេះ ហៅថា អធិបត្យារម្មណ៍ ឬ អារម្មណាធិបតី បានដល់ ឥដ្ឋារម្មណ៍ ។

## ឥដ្ឋារម្មណ៍ មាន ២ យ៉ាង

១-សភាវៈឥដ្ឋារម្មណ៍ ២-បរិកប្បិដ្ឋារម្មណ៍

សភាវៈឥដ្ឋារម្មណ៍ បានដល់ អារម្មណ៍ដែលល្អ ដែលគួរត្រេកអរ គួរប្រាថ្នា ដោយសភាវៈ ដូចរូប សំឡេង ក្លិន រសផោដ្ឋព្វៈជាដើមដែលល្អ ជាអារម្មណ៍ដែលគួរត្រេកអរដល់ជនទូទៅ, ។ ចំណែកបរិកប្បឥដ្ឋារម្មណ៍ បានដល់ អារម្មណ៍ដែលគួរត្រេកអរ គួរប្រាថ្នាចំពោះសត្វ ឬចំពោះបុគ្គល, មិនទូទៅដល់សត្វ និងបុគ្គលទាំងអស់ទេ ជាអារម្មណ៍ ដែលល្អ ដែលពេញចិត្ត តែចំពោះខ្លួនប៉ុណ្ណោះ ។

## សម្តែងទ្វារិកចិត្ត ដោយអារម្មណ៍ ៦

១-ចក្ខុទ្វារិកចិត្ត មាន ៤៦ មានរូបបរមត្ថបច្ចុប្បន្ន ជាអារម្មណ៍ ។

២-សោតទ្វារិកចិត្ត មាន ៤៦ មានសទ្ទបរមត្ថបច្ចុប្បន្ន ជាអារម្មណ៍ ។

៣-ឃានទ្វារិកចិត្ត មាន ៤៦ មានគន្ធបរមត្ថបច្ចុប្បន្ន ជាអារម្មណ៍ ។

៤-ជិវ្ហាទ្វារិកចិត្ត មាន ៤៦ មានរសបរមត្ថបច្ចុប្បន្ន ជាអារម្មណ៍ ។

៥-កាយទ្វារិកចិត្ត មាន ៤៦ មានផោដ្ឋព្វបរមត្ថ បច្ចុប្បន្ន ជាអារម្មណ៍ ។

៦-មនោទ្វារិកចិត្ត មាន ៦៧ ឬ ៩៩ មានអារម្មណ៍ ៦ ជាបច្ចុប្បន្ន អតីតៈ អនាគត និងកាលវិមុត្តារម្មណ៍ តាមសមគួរ ។

មនោទ្វារិកចិត្ត មាន ៦៧ ឬ ៩៩ នោះ គឺ កាមាវចរចិត្ត៤១ (វៀរទ្វិបញ្ចវិញ្ញាណ១០ មនោធាតុ៣) មហគ្គតកុសលចិត្ត និងកិរិយាចិត្ត ១៨ លោកុត្តរចិត្ត ៨ ឬ ៤០ ។

៧-ទ្វារវិមុត្តចិត្ត ចិត្តផុតចាកទ្វារ ដែលធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច និងចុតិកិច្ច, អារម្មណ៍ណាមួយ ក្នុងបណ្តាអារម្មណ៍ ៦ ដែលហៅថា កម្មារម្មណ៍ កម្មនិមិត្តារម្មណ៍ និងគតិនិមិត្តារម្មណ៍ ដែលជាបច្ចុប្បន្ន អតីតៈ និងបញ្ញត្យារម្មណ៍ ដែលកើតតាមទ្វារ ៦ ក្នុងខណៈមរណាសន្នជវនវិថី ក្នុងភពមុន បានចិត្ត ១៩ គឺ ឧបេក្ខាសន្តីរណចិត្ត២ មហាវិបាកចិត្ត៨ មហគ្គតវិបាកចិត្ត៩ ។

## តិកាលិក និងកាលវិមុត្ត

តិកាលិក (អារម្មណ៍ប្រកបដោយកាល ៣) គឺ បច្ចុប្បន្នកាល អតីតកាល អនាគតកាល ។

**បច្ចុប្បន្នារម្មណ៍** បានដល់ ចិត្ត ចេតសិក រូប ដែលកំពុងប្រាកដ ជាអារម្មណ៍ចំពោះមុខ គឺ កំពុងឃើញ កំពុងបាន

ឮ កំពុងធុំក្លិន កំពុងភ្លក់រស កំពុងពាល់ត្រូវសម្ផស្ស និងកំពុងគិត ក្នុងអារម្មណ៍ដែលនៅមិនទាន់រលត់ ។

***អតីតារម្មណ៍*** បានដល់ ចិត្ត ចេតសិក រូប ដែលកន្លងផុតទៅហើយ គឺ បានឃើញហើយ បានឮហើយជាដើម ។

***អនាគតារម្មណ៍*** បានដល់ ចិត្តចេតសិករូប ដែលនឹងកើតប្រាកដក្នុងកាលខាងមុខ ។

***កាលវិមុត្តារម្មណ៍*** អារម្មណ៍ដែលផុតចាកកាល៣ បានដល់ និព្វាន និងបញ្ញត្តិ ព្រោះធម៌ទាំង ២ នេះ មិនមានបច្ច័យតាក់តែងឱ្យកើតឡើង ដូច្នេះ ទើបមិនប្រកបដោយកាល ។

## ទ្វារវិមុត្តចិត្តមានអារម្មណ៍ ៣ យ៉ាង

*១-កម្មារម្មណ៍ ២-កម្មនិមិត្តារម្មណ៍ ៣-គតិនិមិត្តារម្មណ៍*

*អារម្មណ៍ដែលប្រាកដតាមទ្វារភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងទ្វារចិត្ត ក្នុងវេលាប្រក្រតី មិនហៅថា មរណាសន្នវិថីទេ, អារម្មណ៍ ៣ មានកម្មារម្មណ៍ជាដើម រមែង*

មិនប្រាកដដល់ព្រះខីណាស្រព ដែលជិតដល់បរិនិព្វាន ព្រោះមិនមានបដិសន្ធិទៀត ដូច្នោះ អារម្មណ៍ ៣ ដែលពោលនេះ ទើបប្រាកដដល់សត្វដែលត្រូវកើតតទៅ ក្នុងភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណឋិតិ ៧ និងសត្តាវាស ៩ ទៀតប៉ុណ្ណោះ ។

**អារម្មណ៍ ៤ ដោយសង្ខេប**

១- កាមារម្មណ៍ បានដល់ កាមារម្មណ៍ទាំង៦

២- មហគ្គតារម្មណ៍ បានដល់ ធម្មារម្មណ៍

៣- បញ្ញត្យារម្មណ៍ បានដល់ ធម្មារម្មណ៍

៤- លោកុត្តរារម្មណ៍ បានដល់ ធម្មារម្មណ៍

**កាមារម្មណ៍** ( ហៅថា **បរិត្តារម្មណ៍** ជាអារម្មណ៍ល្អិតតូច បានដល់ កាមាវចរចិត្ត ៥៤ ចេតសិក ៥២ រូប ២៨ ទាំងនេះ យ៉ាងណាមួយ ជាអារម្មណ៍របស់ចិត្តក្នុងខណៈនោះ ។

**មហគ្គតារម្មណ៍** ( អារម្មណ៍ដែលដល់ភាពជាធំ ) បាន

ដល់ មហគ្គតចិត្ត ២៧ ចេតសិក ៣៥ ដែល ប្រកបទាំងនេះ យ៉ាងណាមួយ ជាអាម្មណ៍ របស់ចិត្ត ។

**បញ្ញត្យារម្មណ៍** បានដល់ បញ្ញត្តិ ២ គឺ អត្ថប្បញ្ញត្តិ និងសទ្ទប្បញ្ញត្តិ យ៉ាងណាមួយ ជាអារម្មណ៍ របស់ចិត្ត ។

***លោកុត្តរារម្មណ៍*** បានដល់ មគ្គចិត្ត ៤ ផលចិត្ត ៤ និង និព្វាន យ៉ាងណាមួយ ជាអារម្មណ៍របស់ចិត្ត ។

## ចិត្តមានអារម្មណ៍ ជាឯកន្តៈ និងអនេកន្តៈ

ចិត្តទទួលចំពោះកាមៈ ចំពោះមហគ្គតៈ ចំពោះបញ្ញត្តិ ចំពោះលោកុត្តរជាអារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ ហៅថា ឯកន្តារម្មណ៍ ។ ចិត្តទទួលអារម្មណ៍បានច្រើនយ៉ាង ហៅថា អនេកន្តារម្មណ៍ ។

*ចិត្តជាឯកន្តារម្មណ៍ មាន ៤ ប្រភេទ គឺ ចិត្តដែលទទួលកាមារម្មណ៍ ១ ទទួលមហគ្គតារម្មណ៍ ១ ទទួលបញ្ញត្យារម្មណ៍ ១ ទទួលលោកុត្តរារម្មណ៍ ១ ។ ចំណែកចិត្តដែលទទួលអារម្មណ៍ទាំងនេះ មាន ៦០ ឬ ៩២ ។*

*ចិត្តជាអនេកន្តារម្មណ៍ មាន ៣ ប្រភេទ គឺ ចិត្តដែលទទួលកាមារម្មណ៍ ១ ទទួលមហគ្គតារម្មណ៍ ១ ទទួលបញ្ញត្យារម្មណ៍ ១ បានដល់ ចិត្តដែលនៅសល់ ២៩ (បន្ថែមអភិញ្ញាចិត្ត ២ ជា ៣១) ទទួលអនេកន្តារម្មណ៍ គឺ ទទួលអារម្មណ៍បានយ៉ាងច្រើន ។*

## សង្គហគាថា

១១ បញ្ចវីស បរិត្តម្ហិ ឆ      ចិត្តានិ មហគ្គតេ
ឯកវីសតិ វោហារេ      អដ្ឋ និព្វានគោចរេ ។

១២ វីសានុត្តរមុត្តម្ហិ      អគ្គមគ្គផលុជ្ឈិតេ
បញ្ច សព្វត្ថ ឆ ចេតិ      សត្តធា តត្ថ សង្គហោ ។

ក្នុងអាលម្ពនសង្គហៈនេះ សង្គ្រោះចិត្តដោយអារម្មណ៍ ទុក ៧ គឺ ក្នុងបរិត្តារម្មណ៍បានចិត្ត ២៥. ក្នុងមហគ្គតារម្មណ៍បានចិត្ត ៦. ក្នុងបញ្ញត្យារម្មណ៍បានចិត្ត ២១. និព្វានារម្មណ៍ បានចិត្ត ៨. និងក្នុងអារម្មណ៍ដែលផុតចាកលោកុត្តរៈបានចិត្ត ២០ ក្នុងអារម្មណ៍ទាំងអស់ (វៀរអរហត្តមគ្គ-ផល)បាន ចិត្ត ៥ និងក្នុងសព្វារម្មណ៍ (អារម្មណ៍គ្រប់យ៉ាង)បានចិត្ត ៦ ។

## អធិប្បាយ សង្គហគាថា

**១-បញ្ចវីស បរិត្តម្ហិ** ក្នុងកាមារម្មណ៍បានចិត្ត ២៥ គឺ

-ទ្វិបញ្ចវិញ្ញាណ ១០ មានអារម្មណ៍ ៥ ជាបច្ចុប្បន្ន

-មនោធាតុ ៣ មានអារម្មណ៍ ៥ ជាបច្ចុប្បន្ន

-សន្តីរណចិត្ត ៣ មហាវិបាកចិត្ត ៨ និងហសិតុប្បាទចិត្ត ១ មានកាមារម្មណ៍ ៦ ជាបច្ចុប្បន្ន អតីត និងអនាគត

**២- ឆ ចិត្តានិ មហគ្គតេ** ក្នុងមហគ្គតារម្មណ៍ បានចិត្ត

៦ គឺ

-វិញ្ញាណញ្ចាយតនកុសលចិត្ត ១ និងវិញ្ញាណញ្ចាយតនវិបាកចិត្ត ១, ទាំង ២ នេះ មានអាកាសានញ្ចាយតនកុសលចិត្តជាអារម្មណ៍ ជាអតីតារម្មណ៍ ។

-វិញ្ញាណញ្ចាយតនកិរិយាចិត្ត១ មានអាកាសានញ្ចាយតនកុសលចិត្ត និងកិរិយាចិត្តជាអារម្មណ៍ ជាអតីតារម្មណ៍ ។

-នេវសញ្ញានាសញ្ញាយតនកុសលចិត្ត ១ នេវសញ្ញានាសញ្ញាយតនវិបាកចិត្ត ១ ទាំង ២ នេះ មានអាកិញ្ចញ្ញាយតនកុសលចិត្តជាអារម្មណ៍ជាអតីតារម្មណ៍ ។

-នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត ១ មានអាកិញ្ចញ្ញាយតនកុសលចិត្ត និងកិរិយាចិត្តជាអារម្មណ៍ ជាអតីតារម្មណ៍ ។

**៣-ឯកវីសតិ វោហារេ** ក្នុងបញ្ញត្តារម្មណ៍ បានចិត្ត ២១ គឺ ៖

រូបាវចរបឋមជ្ឈានចិត្ត ៣ ( កុសល វិបាក កិរិយា )
រូបាវចរទុតិយជ្ឈានចិត្ត ៣ ( កុសល វិបាក កិរិយា )
រូបាវចរតតិយជ្ឈានចិត្ត ៣ ( កុសល វិបាក កិរិយា )
រូបាវចរចតុត្ថជ្ឈានចិត្ត ៣ ( កុសល វិបាក កិរិយា )
រូបាវចរបញ្ចមជ្ឈានចិត្ត ៣ ( កុសល វិបាក កិរិយា )
អាកាសានញ្ចាយតនជ្ឈានចិត្ត៣ ( កុសល វិបាក កិរិយា )
អាកិញ្ចញ្ញាយតនជ្ឈានចិត្ត ៣ ( កុសល វិបាក កិរិយា )

អារម្មណ៍របស់បឋមជ្ឈានចិត្ត ៣ មាន ២៥ យ៉ាងគឺ កសិណបញ្ញត្តិ ១០ អសុភបញ្ញត្តិ ១០ កោដ្ឋាសបញ្ញត្តិ ១ អានាបានបញ្ញត្តិ១ បិយមនាបសត្តបញ្ញត្តិ១ ទុក្ខិតសត្តបញ្ញត្តិ ១ និងសុខិតសត្តបញ្ញត្តិ ១ ។

អារម្មណ៍របស់ទុតិយជ្ឈានចិត្ត ដល់ចតុត្ថជ្ឈានចិត្ត មាន បញ្ញត្យារម្មណ៍ ១៤ គឺ កសិណបញ្ញត្តិ ១០ អានាបានបញ្ញត្តិ ១ បិយមនាបសត្តបញ្ញត្តិ ១ ទុក្ខិតសត្តបញ្ញត្តិ ១ សុខិត

សត្តប្បញ្ញត្តិ ១ ។

អារម្មណ៍របស់រូបាវចរបញ្ចមជ្ឈានចិត្ត ៣ មានបញ្ញត្តិជាអារម្មណ៍ ១២ យ៉ាង គឺ កសិណាប្បញ្ញត្តិ ១០ អានាបានប្បញ្ញត្តិ ១ មជ្ឈត្តសត្តប្បញ្ញត្តិ ១ ។

អរូបជ្ឈានទី ១ គឺ អាកាសានញ្ចាយតនចិត្ត ៣ មានកសិណុគ្ឃាដិមាកាសប្បញ្ញត្តិជាអារម្មណ៍ ជាធម្មារម្មណ៍ ។

អាកិញ្ចញ្ញាយតនចិត្ត ៣ មាននត្ថិភាវបញ្ញត្តិ ជាអារម្មណ៍ និងជាធម្មារម្មណ៍ប៉ុណ្ណោះ ។

ចិត្តទាំង ២១ មានបញ្ញត្តិធម្មារម្មណ៍ជាអារម្មណ៍ និងជាកាលវិមុត្ត ( ផុតចាកកាល ) ។

**៤-អដ្ឋ និព្វានគោចរេ** ក្នុងនិព្វានអារម្មណ៍ បានចិត្ត ៨ ឬ ៤០ គឺ -

លោកុត្តរចិត្ត៨ គឺ មគ្គ៤ ផល៤ ( ដោយពិស្តារ៤០ ) មាននិព្វានជាអារម្មណ៍ ជាធម្មារម្មណ៍ និងផុតចាកកាល ។

រួមចិត្ត ៦០ ឬ ៩២ មានអារម្មណ៍ ជាឯកន្តៈ ( ពិតប្រាកដ )

**៥-វិសានុត្តរមុត្តម្ហិ** ក្នុងអារម្មណ៍ដែលផុតចាកលោកុត្តរធម៌ បានចិត្ត ២០ គឺ -

អកុសលចិត្ត ១២ មហាកុសលញាណវិប្បយុត្តចិត្ត ៤ មហាកិរិយាញាណវិប្បយុត្តចិត្ត ៤ ។ ចិត្ត ២០ នេះ មានកាមារម្មណ៍ ៦ ដែលជាបច្ចុប្បន្ន អតីតៈ អនាគត ក៏បាន មានមហគ្គតារម្មណ៍ដែលជាអតីតារម្មណ៍ ក៏បាន មានបញ្ញត្តិធម្មារម្មណ៍ដែលជាកាលវិមុត្តារម្មណ៍ក៏បាន ។

**៦-អគ្គមគ្គផលុជ្ឈិតេ** ក្នុងអារម្មណ៍ទាំងអស់ ( វៀរអរហត្តមគ្គ អរហត្តផល ) បានចិត្ត ៥ គឺ ៖

មហាកុសលញាណសម្បយុត្តចិត្ត៤ កុសលអភិញ្ញាចិត្ត ១ ។ ចិត្ត ៥ នេះ មានអារម្មណ៍ ៦ ជាលោកិយៈដែលជាបច្ចុប្បន្ន អតីតៈ អនាគត បញ្ញត្តិ និងលោកុត្តរធម៌ ( វៀរ

អរហត្តមគ្គ អរហត្តផល ) ជាអារម្មណ៍ ។

**៧-សព្វត្ថ ឆ ច** ក្នុងសព្វារម្មណ៍ ( អារម្មណ៍គ្រប់យ៉ាង ) បានចិត្ត ៦ គឺ -

មនោទ្វារាវជ្ជនចិត្ត ១ មហាកិរិយាញាណសម្បយុត្ត ៤ កិរិយាអភិញ្ញាចិត្ត ១ ។ ចិត្ត ៦ នេះ មានអារម្មណ៍ ៦ ដែលជាលោកិយារម្មណ៍ បញ្ញត្តិ និងលោកុត្តរធម៌ដែលជាបច្ចុប្បន្ន អតីតៈ អនាគត និងកាលវិមុត្ត ជាអារម្មណ៍ ។

ក្នុងបណ្ដាអារម្មណ៍ ៧ នោះ គឺ

➡ ចិត្ត ២៥ មានកាមជាអារម្មណ៍ បានដល់ ទ្វិបញ្ចវិញ្ញាណ១០ មានអារម្មណ៍បានចំពោះរបស់ខ្លួន ៗ និងមនោធាតុ ៣ ( បញ្ចទ្វារាវជ្ជន ១ វិបាកមនោធាតុ ២ ) នេះ អាចទទួលអារម្មណ៍ បាន ៥ អារម្មណ៍ និងជាបច្ចុប្បន្នារម្មណ៍តែម្យ៉ាងដូចគ្នា ។ តែចិត្ត ១២ គឺ សន្តីរណចិត្ត ៣ មហាវិបាកចិត្ត ៨ ហសិតុប្បាទចិត្ត ១ ទទួលអារម្មណ៍បានទាំង ៦ និងជាបច្ចុប្បន្ន

ជាអតីត ឬអនាគត ក៏បាន ។

➡ ចិត្ត ៦ ដែលមានមហគ្គតជាអារម្មណ៍ គឺ វិញ្ញាណញ្ចាយតនកុសល ១ វិបាក ១ និងកិរិយា ១ ។ គប្បីជ្រាបពាក្យអធិប្បាយ ដូចតទៅនេះ ៖

-អ្នកបានអាកាសានញ្ចាយតនជ្ឈានហើយ នឹងចម្រើនសមថៈ ដើម្បីឱ្យវិញ្ញាណញ្ចាយតនជ្ឈានកើតក្តី ឬអ្នកបាននូវវិញ្ញាណញ្ចាយតនជ្ឈានហើយ នឹងចូលវិញ្ញាណញ្ចាយតនជ្ឈានទៀតក្តី នឹងត្រូវមានអាកាសានញ្ចាយតនកុសលចិត្ត ឬអាកាសានញ្ចាយតនកិរិយាចិត្តដែលបានហើយជាអារម្មណ៍ វិញ្ញាណញ្ចាយតនជ្ឈាន ទើបកើតឡើង ។

-បុថុជ្ជនក្តី ផលសេក្ខបុគ្គលក្តី ដែលបានវិញ្ញាណញ្ចាយតនជ្ឈាន កាលនឹងឱ្យវិញ្ញាណញ្ចាយតនកុសលកើតឡើង ក៏ត្រូវមានអាកាសានញ្ចាយតនកុសល ដែលធ្លាប់កើតដល់ខ្លួនក្នុងភពនេះ ជាអារម្មណ៍ ។ កាលព្រះយោគីមរណៈ បដិសន្ធិដោយ

វិញ្ញាណញ្ចាយតនវិបាកចិត្ត សូម្បីបដិសន្ធិចិត្តរបស់គេ ក៏មាន អាកាសានញ្ចាយតនកុសល ដែលខ្លួនបានក្នុងភពមុននោះឯងជា អារម្មណ៍ ចិត្តដែលធ្វើភវង្គកិច្ចក្តី ធ្វើចុតិកិច្ចក្តី ក៏មានអាកាសានញ្ចាយតនកុសល ដែលខ្លួនបានក្នុងភពមុន ជាអារម្មណ៍ ។

-ព្រះយោគីអ្នកបានអរូបជ្ឈាន ចម្រើនវិបស្សនាកម្មដ្ឋាន សម្រេចជាព្រះអសេក្ខបុគ្គលហើយ កាលចូលវិញ្ញាណញ្ចាយតនជ្ឈានដែលធ្លាប់បានមក ឈានដែលចូលថ្មីនេះ ជាវិញ្ញាណញ្ចាយតនកិរិយាចិត្ត និងវិញ្ញាណញ្ចាយតនកិរិយាចិត្ត ដែលកើតឡើងនេះ ក៏មានអាកាសានញ្ចាយតនកុសលចិត្តដែលខ្លួនបានហើយក្នុងភពនេះ ជាអារម្មណ៍ ។

ម្យ៉ាងទៀត ព្រះអរហន្តដែលបានអរូបជ្ឈាន ចូលអាកាសានញ្ចាយតនជ្ឈានហើយ ឈាននេះ ក៏ជាអាកាសានញ្ចាយតនកិរិយាឈាន, តែកាលចូលវិញ្ញាណញ្ចាយតនកិរិយាឈានតទៅ វិញ្ញាណញ្ចាយតនកិរិយាឈាននេះ ក៏មានអាកាសានញ្ចា

យតនកិរិយាចិត្តនោះឯង ជាអារម្មណ៍ ។

ក្នុងនេវសញ្ញានាសញ្ញាយតនជ្ឈាន ដែលជាកុសលចិត្ត ១ វិបាកចិត្ត ១ កិរិយាចិត្ត ១ ក៏មានន័យដូចគ្នា ។

➡ ចិត្ត ២១ មានបញ្ញត្តិជាអារម្មណ៍ គឺ

-រូបាវចរ ១៥ ដែលធ្វើការសម្លឹងអារម្មណ៍បញ្ញត្តិក្នុងកម្មដ្ឋាន ២៦ ប្រការ គឺ កសិណបញ្ញត្តិ ១០ អសុភបញ្ញត្តិ ១០ អាបានាបញ្ញត្តិ ១ កាយគតាបញ្ញត្តិ ១ បិយមនាបសត្តបញ្ញត្តិ ១ ទុក្ខិតសត្តបញ្ញត្តិ ១ សុខិតសត្តបញ្ញត្តិ ១ និងមជ្ឈត្តសត្តបញ្ញត្តិ ១ ។

-អាកាសានញ្ចាយតនចិត្ត ៣ មានកសិណុគ្ឃាដិមាកាសបញ្ញត្តិជាអារម្មណ៍ ។

-អាកិញ្ចញ្ញាយតនជ្ឈានចិត្ត ៣ មាននត្ថិភាវបញ្ញត្តិ ជាអារម្មណ៍

+ រួមជាចិត្ត ២១ ។

➡ លោកុត្តចិត្ត ៨ មានតែនិព្វាន ជាអារម្មណ៍ ។

➡ ចិត្តដែលទទួលអារម្មណ៍បានមួយប្រភេទ មាន៦០ គឺ

១-ចិត្តដែលទទួលកាម ជាអារម្មណ៍ ២៥

២-ចិត្តដែលទទួលមហគ្គត ជាអារម្មណ៍ ៦

៣-ចិត្តដែលទទួលបញ្ញត្តិ ជាអារម្មណ៍ ២១

៤-ចិត្តដែលទទួលនិព្វាន ជាអារម្មណ៍ ៨

➡ ចិត្តដែលនៅសល់ ២៩ បើរួមទឹងអភិញ្ញា ២ ដែលជាចិត្តពិសេស ក៏បានចិត្ត ៣១, ចិត្តទាំងនោះ ទទួលអារម្មណ៍បានច្រើនយ៉ាង បែងជា ៣ ប្រភេទ គឺ ៖

១-ចិត្ត ២០ ទទួលកាមារម្មណ៍បាន ៦ ដែលប្រព្រឹត្តទៅក្នុងកាលទាំង ៣, ទទួលមហគ្គតារម្មណ៍ដែលជាអតីត, ទទួលបញ្ញត្យារម្មណ៍ដែលជាកាលវិមុត្តក៏បាន ( វៀរលោកុត្តារម្មណ៍ )

២-ចិត្ត ៥ ( វៀរអរហត្តមគ្គផល ) ទទួលអារម្មណ៍

បានច្រើន ជាងចិត្ត ២០ ដែលពោលហើយនោះ ។[១]

៣-ចិត្ត ៦ ទទួលអារម្មណ៍បានគ្រប់យ៉ាង ។[២]

## សរុបឯកគ្គៈ និងអនេកគ្គៈ

ឯកគ្គៈ មានចិត្ត ៦០ ទទួលអារម្មណ៍បានតែមួយប្រភេទ

អនេកគ្គៈ មានចិត្ត ២៩ ទទួលអារម្មណ៍បានច្រើនយ៉ាង ។

អភិញ្ញាចិត្ត ២ ដែលកើតអំពីរូបាវចរបញ្ចមជ្ឈានចិត្ត មាន ២ យ៉ាង គឺ អភិញ្ញាសាមញ្ញ និងអភិញ្ញាវិសេស ។

អភិញ្ញាសាម័ញ្ញនោះ ទទួលអារម្មណ៍តាមប្រក្រតីរបស់ឈាន, ចំណែកអភិញ្ញាវិសេសនោះ ជាចិត្តដែលដឹងវិសេស ព្រោះអំណាចការហ្វឹកហាត់ចិត្ត ដោយអាការ ១៤ យ៉ាង និង អភិញ្ញាចិត្តនេះ ក៏មាន ២ គឺ កុសលអភិញ្ញាដែលជាចិត្ត តិហេតុកបុថុជ្ជន និងព្រះសេក្ខបុគ្គលដែលបានអភិញ្ញា និងកិរិយា

---

១. ចូរមើលក្នុងទំព័រ ៦៦-៧ ។ ២. ចូរមើលក្នុងទំព័រ ៦៧ ។

អភិញ្ញា ដែលជាចិត្តរបស់ព្រះខីណាស្រពដែលបានអភិញ្ញា ។

## អារម្មណ៍ដោយពិស្តារ ២១ យ៉ាង

១-កាមារម្មណ៍ បានដល់ កាមចិត្ត ៥៤ ចេតសិក ៥២ រូប ២៨ ( បាន ៦ អារម្មណ៍ )

២-មហគ្គតារម្មណ៍ បានដល់ មហគ្គតចិត្ត ២៧ ចេតសិក ៣៥ ( ជាធម្មារម្មណ៍ ) ។

៣-និព្វានារម្មណ៍ បានដល់ និព្វានជាអារម្មណ៍ ( ជាធម្មារម្មណ៍ ) ។

៤-នាមារម្មណ៍ បានដល់ ចិត្ត ចេតសិក និព្វាន ( ជាធម្មារម្មណ៍ ) ។

៥-រូបអារម្មណ៍[១] បានដល់ រូប ២៨ ( បាន ៦

១. មិនភ្ជាប់ជារូបារម្មណ៍ ព្រោះកុំឱ្យដូចរូបារម្មណ៍ជារូបពណ៌ទី ១៦ ជាចិត្តមានចំនួនខុសគ្នា ។

អារម្មណ៍ )

៦-បច្ចុប្បន្នារម្មណ៍ បានដល់ ចិត្ត ចេតសិក រូប កំពុងកើត ( បាន ៦ អារម្មណ៍ )

៧-អតីតារម្មណ៍ បានដល់ ចិត្ត ចេតសិក រូប ដែលរលត់ហើយ ( បាន ៦ អារម្មណ៍ )

៨-អនាគតារម្មណ៍ បានដល់ ចិត្ត ចេតសិក រូប ដែលនឹងកើត ( បាន ៦ អារម្មណ៍ )

៩-កាលវិមុត្តារម្មណ៍ បានដល់ និព្វាន និងបញ្ញត្តិ( ជាធម្មារម្មណ៍ ) ។

១០-បញ្ញត្តារម្មណ៍ បានដល់ អត្ថប្បញ្ញត្តិ និងសទ្ទប្បញ្ញត្តិ ( ជាធម្មារម្មណ៍ )

១១-បរមត្ថារម្មណ៍ បានដល់ ចិត្ត ចេតសិក រូប និព្វាន ( បាន ៦ អារម្មណ៍ )

១២-អជ្ឈត្តារម្មណ៍ បានដល់ ចិត្ត ចេតសិក រូប ដែល

កើតក្នុងខ្លួន ( បាន ៦ អារម្មណ៍ )

១៣-ពហិទ្ធារម្មណ៍ បានដល់ ចិត្ត ចេតសិក រូប ដែលកើតដល់អ្នកដទៃ ( បាន ៦ អារម្មណ៍ )

១៤-អជ្ឈត្តពហិទ្ធារម្មណ៍ បានដល់ ចិត្ត ចេតសិក រូប ដែលកើតក្នុងខ្លួន និងអ្នកដទៃ( បាន ៦ អារម្មណ៍ )

១៥-បញ្ញារម្មណ៍ បានដល់ វិសយរូប ៧ ( បាន៥ អារម្មណ៍ )

១៦-រូបារម្មណ៍ បានដល់ ពណ៌ផ្សេង ៗ ( បាន១ អារម្មណ៍ )

១៧-សទ្ទារម្មណ៍ បានដល់ សំឡេងផ្សេង ៗ

១៨-គន្ធារម្មណ៍ បានដល់ ក្លិនផ្សេង ៗ

១៩-រសារម្មណ៍ បានដល់ រសផ្សេង ៗ

២០-ផោដ្ឋព្វារម្មណ៍ បានដល់ ត្រជាក់ ក្តៅ ទន់ រឹង តឹង ញ័រ ( បាន ១ អារម្មណ៍ )

២១-ធម្មារម្មណ៍ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ ប្រសាទរូប ៥ សុខុមរូប ១៦ និព្វាន បញ្ញត្តិ ។

(ធម្មារម្មណ៍នេះ ក្នុងដីកាអភិធម្មាវតារថែមលក្ខណៈ ៣ គឺ អនិច្ច ទុក្ខ អនត្តាទៀត)

## ចិត្តទទួលអារម្មណ៍ដោយពិស្តារ ២១ យ៉ាង

១. ចិត្តដែលទទួលកាមារម្មណ៍ មាន ៥៦ គឺ កាមាវចរចិត្ត ៥៤ អភិញ្ញាចិត្ត ២

២. ចិត្តដែលទទួលមហគ្គតារម្មណ៍ មាន ៣៧ គឺ អកុសលចិត្ត១២ មនោទ្វារាវជ្ជនចិត្ត១ មហាកុសលចិត្ត៨ មហាកិរិយាចិត្ត៨ អភិញ្ញាចិត្ត២ វិញ្ញាណញ្ចាយតនជ្ឈានចិត្ត៣ នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត៣

៣. ចិត្តដែលមាននិព្វាន ជាអារម្មណ៍ មាន ១៩ គឺ - មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលញាណសម្បយុត្តចិត្ត ៤ មហាកិរិយាញាណសម្បយុត្តចិត្ត៤ អភិញ្ញាចិត្ត២ លោកុត្តរចិត្ត៨

៤. ចិត្តដែលមាននាមជាអារម្មណ៍ មាន ៥៧ គឺ អកុសលចិត្ត១២, សន្តីរណចិត្ត៣, មនោទ្វារាវជ្ជនចិត្ត១, ហសិតុប្បាទចិត្ត ១ , កាមាវចរសោភណចិត្ត ២៤, អភិញ្ញាចិត្ត ២, វិញ្ញាណញ្ចាយតនជ្ឈានចិត្ត ៣, នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត ៣, លោកុត្តរចិត្ត ៨ ។

៥. ចិត្តដែលទទួលរូបជាអារម្មណ៍ មាន ៥៦ គឺ កាមាវចរចិត្ត ៥៤ អភិញ្ញាចិត្ត ២

៦. ចិត្តដែលទទួលបច្ចុប្បន្នារម្មណ៍ មាន ៥៦ គឺ កាមាវចរចិត្ត ៥៤ អភិញ្ញាចិត្ត ២

៧. ចិត្តដែលទទួលអតីតារម្មណ៍ មាន ៤៩ គឺ - អកុសលចិត្ត១២, សន្តីរណចិត្ត៣, មនោទ្វារាវជ្ជនចិត្ត១, ហសិតុប្បាទចិត្ត១, កាមាវចរសោភណចិត្ត២៤, អភិញ្ញាចិត្ត២, វិញ្ញាណញ្ចាយតនជ្ឈានចិត្ត៣, នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត៣,

៨. ចិត្តដែលមានអនាគតជាអារម្មណ៍មាន ៤៣ គឺ -

អកុសលចិត្ត ១២, សន្តីរណចិត្ត ៣, មនោទ្វារាវជ្ជនចិត្ត ១ ហសិតុប្បាទចិត្ត១, កាមាវចរសោភណចិត្ត២៤, អភិញ្ញាចិត្ត២

៩. ចិត្តដែលមានកាលវិមុត្ត ជាអារម្មណ៍ មាន ៦០ គឺ អកុសលចិត្ត១២, មនោទ្វារាវជ្ជនចិត្ត១, មហាកុសលចិត្ត៨, មហាកិរិយាចិត្ត៨, រូបាវចរចិត្ត១៥, អភិញ្ញាចិត្ត២, អាកាសានញ្ចាយតនជ្ឈានចិត្ត៣, អាកិញ្ចញ្ញាយតនជ្ឈានចិត្ត៣, លោកុត្តរចិត្ត ៨

១០. ចិត្តដែលមានបញ្ញត្តិជាអារម្មណ៍ មាន ៥២ (វៀរ លោកុត្តរ ៨ ដែលនៅសល់ដូចទី៩)

១១. ចិត្តដែលមានបរមត្ថ ជាអារម្មណ៍ មាន ៧០ គឺ - កាមាវចរចិត្ត៥៤, អភិញ្ញាចិត្ត២, វិញ្ញាណញ្ចាយតនជ្ឈានចិត្ត ៣, នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត៣ លោកុត្តរចិត្ត៨

១២. ចិត្តដែលមានអជ្ឈត្តៈជាអារម្មណ៍ មាន ៦២ គឺ កាមាវចរចិត្ត ៥៤, អភិញ្ញាចិត្ត ២, វិញ្ញាណញ្ចាយតនជ្ឈានចិត្ត

៣, នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត ៣

១៣. ចិត្តដែលមានពហិទ្ធៈ ជាអារម្មណ៍ មាន ៨២ គឺ កាមាវចរចិត្ត ៥៤, រូបាវចរចិត្ត ១៥, អភិញ្ញាចិត្ត ២, អាកាសានញ្ចាយតនជ្ឈានចិត្ត ៣, លោកុត្តរចិត្ត ៨

១៤. ចិត្តដែលមានអជ្ឈត្តពហិទ្ធធម៌ជាអារម្មណ៍ មាន ៥៦ គឺ កាមាវចរចិត្ត ៥៤ អភិញ្ញាចិត្ត ២

១៥. ចិត្តដែលមានរូប( ពណ៌ )ជាអារម្មណ៍ មាន ៤៨ គឺ អកុសលចិត្ត១២, ចក្ខុវិញ្ញាណ២, មនោធាតុ៣, សន្តីរណចិត្ត៣, មនោទ្វារាវជ្ជនចិត្ត ១, ហសិតុប្បាទចិត្ត ១, កាមាវចរសោភណចិត្ត ២៤, អភិញ្ញាចិត្ត ២

១៦. ចិត្តដែលមានសទ្ទៈ( សំឡេង )ជាអារម្មណ៍ មាន ៤៨ ( ដូចទី ១៥ ប្តូរតែចក្ខុវិញ្ញាណ ជាសោតវិញ្ញាណ )

១៧. ចិត្តដែលមានគន្ធៈ( ក្លិន )ជាអារម្មណ៍មាន ៤៨ ( ដូចទី ១៥ ប្តូរតែចក្ខុវិញ្ញាណ ជាឃានវិញ្ញាណ )

១៨. ចិត្តដែលមានរស (រសជាតិ) ជាអារម្មណ៍ មាន ៤៨ (ដូចទី ១៥ ប្តូរតែចក្ខុវិញ្ញាណ ជាជិវ្ហាវិញ្ញាណ)

១៩. ចិត្តដែលមានផោដ្ឋព្វ (សម្ផស្ស) ជាអារម្មណ៍ មាន ៤៨ (ដូចទី ១៥ ប្តូរត្រៃចក្ខុវិញ្ញាណ ជាកាយវិញ្ញាណ)

២០. ចិត្តដែលមានបញ្ចារម្មណ៍ ជាអារម្មណ៍ មាន ៤៦ គឺ កាមាវចរចិត្ត៤៤ (វៀរទ្វិបញ្ចវិញ្ញាណ១០) អភិញ្ញាចិត្ត២

២១. ចិត្តដែលមានធម្មារម្មណ៍ជាអារម្មណ៍ មាន ៧៨ គឺ កាមាវចរចិត្ត ៤១ (វៀរទ្វិបញ្ចវិញ្ញាណ ១០, មនោធាតុ ៣) រូបាវចរចិត្ត ១៥ អភិញ្ញាចិត្ត ២ អរូបាវចរចិត្ត ១២ លោកុត្តរចិត្ត ៨ ។

**សម្តែងចេតសិកដែលទទួលអារម្មណ៍** ( ឯកន្តៈ និងអនេកន្តៈ )

១-ចេតសិកដែលមានកាមជាអារម្មណ៍ ដោយមិនប្រាកដ មាន ៥០ ( វៀរអប្បមញ្ញា ២ )

២-ចេតសិកដែលមានមហគ្គតៈជាអារម្មណ៍ ដោយមិនប្រាកដ មាន ៤៧ ( វៀរវិរតិ ៣ អប្បមញ្ញា ២ )

៣-ចេតសិកដែលមាននិព្វានជាអារម្មណ៍ ដោយមិនប្រាកដ មាន ៣៦ គឺ - អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២៣ ( វៀរអប្បមញ្ញា ២ )

៤-ចេតសិកដែលមាននាមជាអារម្មណ៍ ដោយមិនប្រាកដ មាន ៥០ ( វៀរអប្បមញ្ញា ២ )

៥-ចេតសិកដែលមានរូបជាអារម្មណ៍ ដោយមិនប្រាកដ មាន ៥០ ( វៀរអប្បមញ្ញា ២ )

៦-ចេតសិកដែលមានអតីតៈជាអារម្មណ៍ ដោយមិនប្រាកដ មាន ៤៧ ( វៀរវិរតិ ៣ អប្បមញ្ញា ២ )

៧-ចេតសិកដែលមានបច្ចុប្បន្នជាអារម្មណ៍ ដោយមិនប្រាកដ មាន ៥០ ( វៀរអប្បមញ្ញា ២ )

៨-ចេតសិកដែលមានអនាគតជាអារម្មណ៍ ដោយមិនប្រាកដ មាន ៥០ ( វៀរអប្បមញ្ញា ២ )

៩-ចេតសិកដែលមានកាលវិមុត្តារម្មណ៍ជាអារម្មណ៍

ដោយពិតប្រាកដ មាន ២ គឺ - អប្បមញ្ញា ២

ដោយមិនប្រាកដ មាន ៥០ ដែលនៅសល់

១០-ចេតសិកដែលមានបញ្ញត្តិជាអារម្មណ៍

ដោយពិតប្រាកដ គឺ - អប្បមញ្ញា ២

ដោយមិនប្រាកដ មាន ៤៧ ( វៀរវិរតិ ៣ )

១១-ចេតសិកដែលមានបរមត្ថជាអារម្មណ៍

ដោយពិតប្រាកដ គឺ - វិរតិ ៣

ដោយមិនប្រាកដ មាន៤៧ ( វៀរអប្បមញ្ញា ២ )

១២-ចេតសិកដែលមានអជ្ឈត្តៈជាអារម្មណ៍

ដោយពិតប្រាកដ មិនមាន

ដោយមិនប្រាកដ មាន ៤៩ (វៀរឥស្សា និង អប្បមញ្ញា ២)

១៣-ចេតសិកដែលមានពហិទ្ធៈជាអារម្មណ៍

ដោយពិតប្រាកដ មាន ៣ គឺ ឥស្សា និង អប្បមញ្ញា ២

ដោយមិនប្រាកដ មាន ៤៩ ដែលនៅសល់

១៤-ចេតសិកដែលមានអជ្ឈត្តៈ និងពហិទ្ធៈជាអារម្មណ៍

ដោយពិតប្រាកដ មិនមាន

ដោយមិនប្រាកដ មាន ៤៩ (វៀរឥស្សា និង អប្បមញ្ញា ២)

១៥-ចេតសិកដែលមានបញ្ញត្តារម្មណ៍ជាអារម្មណ៍

ដោយពិតប្រាកដ មិនមាន

ដោយមិនប្រាកដ មាន៥០ (វៀរអប្បមញ្ញា២)

១៦-ចេតសិកដែលមានធម្មារម្មណ៍ជាអារម្មណ៍

ដោយពិតប្រាកដ មាន គឺ អប្បមញ្ញា ២

ដោយមិនប្រាកដ មាន ៥០ ។

១៧-អកុសលចេតសិក ១៤ ទទួលអារម្មណ៍ ៦ ដែលជាលោកិយៈ និងបញ្ញត្យារម្មណ៍

១៨-ឥស្សាចេតសិក ១ ទទួលអារម្មណ៍ ៦ ដែលជាពហិទ្ធារម្មណ៍

១៩-លោកិយវិរតិ ៣ ទទួលអារម្មណ៍ ៦ ដែលជាកាមារម្មណ៍

២០-លោកុត្តរវិរតិ ៣ ទទួលនិព្វានជាអារម្មណ៍

២១-អប្បមញ្ញា ២ ទទួលធម្មារម្មណ៍ដែលជាបញ្ញត្តិ គឺសត្វ បុគ្គល និង ជាពហិទ្ធារម្មណ៍ ។

២២-អញ្ញសមានា ១៣ សោភណសាធារណចេតសិក ១៩ និងបញ្ញាចេតសិក ១ ទទួលអារម្មណ៍ ៦ ដែលជាលោកិយៈ លោកុត្តរៈ អតីតៈ បច្ចុប្បន្ន អនាគត កាលវិមុត្ត អជ្ឈត្តៈ និងពហិទ្ធៈ ។

## សរុបចិត្តទទួលអារម្មណ៍ ៨ ន័យ

១-ចិត្ត ១៣ ដែលមានបច្ចុប្បន្នធម៌ ជាអារម្មណ៍ គឺ ទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុ ៣

២-ចិត្ត ១២ ដែលជាតេកាលិកធម៌ (អតីត បច្ចុប្បន្ន អនាគត)ជាអារម្មណ៍ គឺ មហាវិបាកចិត្ត ៨ សន្តីរណចិត្ត ៣ ហសិតុប្បាទចិត្ត ១

៣-ចិត្ត ២០ ដែលមានលោកិយធម៌និងបញ្ញត្តិ ជាអារម្មណ៍គឺ អកុសលចិត្ត ១២ មហាកុសលញាណវិប្បយុត្តចិត្ត ៤ មហាកិរិយាញាណវិប្បយុត្តចិត្ត ៤

៤-ចិត្ត ៥ ដែលទទួលអារម្មណ៍ បានអស់(វៀរអរហត្តមគ្គផល)គឺ មហាកុសលញាណសម្បយុត្តចិត្ត ៤ កុសលអភិញ្ញាចិត្ត ១

៥-ចិត្ត ៦ ដែលទទួលអារម្មណ៍ បានទាំងអស់ គឺ មនោទ្វារាវជ្ជនចិត្ត ១ មហាកិរិយាញាណសម្បយុត្តចិត្ត ៤

កិរិយាអភិញ្ញាចិត្ត ១

៦-ចិត្ត ២១ មានបញ្ញត្តិ ជាអារម្មណ៍ គឺ រូបាវចរឈានចិត្ត ១៥ អាកាសានញ្ចាយតនជ្ឈានចិត្ត ៣ អាកិញ្ចញ្ញាយតនជ្ឈានចិត្ត ៣

៧-ចិត្ត ៦ មានមហគ្គតៈ ជាអារម្មណ៍ គឺ -

វិញ្ញាណញ្ចាយតនជ្ឈានចិត្ត ៣

នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត ៣

៨-ចិត្ត ៨ មាននិព្វាន ជាអារម្មណ៍ គឺ លោកុត្តរចិត្ត៨

សម្តែងចិត្តដែលអាចដឹងអារម្មណ៍ផ្សេង ៗ ៨ ន័យ

១-ចិត្ត ២៨ ទទួលអារម្មណ៍បាន ១ យ៉ាង

២-ចិត្ត ២ ទទួលអារម្មណ៍បាន ២ យ៉ាង

៣-ចិត្ត ៣ ទទួលអារម្មណ៍បាន ៥ យ៉ាង

៤-ចិត្ត ៤១ ទទួលអារម្មណ៍បាន ៦ យ៉ាង

៥-ចិត្ត ៣ ទទួលអារម្មណ៍បាន ១២ យ៉ាង

អធិប្បាយសង្គហគាថាទី១១-១២ អារម្មណសង្គហៈ

៦-ចិត្ត ៩ ទទួលអារម្មណ៍បាន ១៤ យ៉ាង

៧-ចិត្ត ៣ ទទួលអារម្មណ៍បាន ២៥ យ៉ាង

៨-ចិត្ត ៦ ទទួលអារម្មណ៍បាន គ្រប់យ៉ាង

## អធិប្បាយចិត្តដែលដឹងអារម្មណ៍ ៨ ន័យ

១-ចិត្ត ២៨ ទទួលអារម្មណ៍ បានតែ ១ គឺ -

-ទ្វិបញ្ចវិញ្ញាណ ១០ ទទួលអារម្មណ៍ចំពោះតែរបស់ខ្លួន

-អាកាសានញ្ចាយតនជ្ឈានចិត្ត ៣ ទទួលកសិណុគ្ឃាដិមាកាសប្បញ្ញត្តិ

-អាកិញ្ចញ្ញាយតនជ្ឈានចិត្ត ៣ ទទួលនត្ថិភាវបញ្ញត្តិ

-វិញ្ញាណញ្ចាយតនកុសលចិត្ត ១ វិបាកចិត្ត ១ ទទួលអាកាសានញ្ចាយតនកុសលចិត្ត

-នេវសញ្ញានាសញ្ញាយតនកុសលចិត្ត ១ វិបាកចិត្ត ១ ទទួលអាកិញ្ចញ្ញាយតនកុសលចិត្ត

-លោកុត្តរចិត្ត ៨ ទទួលព្រះនិព្វានជាអារម្មណ៍

២-ចិត្ត ២ ទទួលអារម្មណ៍បាន ២ យ៉ាង គឺ -

-វិញ្ញាណញ្ចាយតនកិរិយាចិត្ត ១ ទទួលអាកាសានញ្ចាយតនកុសលដែលកើតដល់ខ្លួន ក្នុងភពនេះ និងភពមុន ជាអារម្មណ៍ ១ និងទទួលអាកាសានញ្ចាយតនកិរិយាចិត្តដែលកើតដល់ខ្លួនក្នុងភពនេះ ជាអារម្មណ៍

-នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត ១ ទទួលអាកិញ្ចញ្ញាយតនកុសល និងកិរិយាចិត្ត ជាអារម្មណ៍ ដូចគ្នានឹងវិញ្ញាណញ្ចាយតនកិរិយាចិត្តនោះឯង ។

៣-ចិត្ត ៣ គឺ មនោធាតុ ៣ ទទួលអារម្មណ៍ ៥ យ៉ាង មានរូបារម្មណ៍ជាដើម ។

៤-ចិត្ត ៤១ ទទួលអារម្មណ៍ បាន ៦ យ៉ាង មានរូបារម្មណ៍ជាដើម គឺ មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ តទាលម្ពនចិត្ត ១១

៥-ចិត្ត ៣ ទទួលអារម្មណ៍ បាន ១២ យ៉ាង គឺ រូបាវចរបញ្ចមជ្ឈានចិត្ត ៣ មានកសិណបញ្ញត្តិ ១០ អានាបានបញ្ញត្តិ

១ និងមជ្ឈត្តសត្តប្បញ្ញត្តិ ១ ជាអារម្មណ៍ ។

៦-ចិត្ត ៩ ទទួលអារម្មណ៍ បាន ១៤ យ៉ាង គឺ រូបាវចរទុតិយជ្ឈានចិត្ត ៣ រូបាវចរតតិយជ្ឈានចិត្ត ៣ រូបាវចរចតុត្ថជ្ឈានចិត្ត ៣ មានអារម្មណ៍ ១៤ គឺ កសិណ ១០ អានាបានប្បញ្ញត្តិ ១ បិយមនាបសត្តប្បញ្ញត្តិ ១ ទុក្ខិតសត្តប្បញ្ញត្តិ ១ និងសុខិតសត្តប្បញ្ញត្តិ ១ ជាអារម្មណ៍ ។

៧-ចិត្ត ៣ ទទួលអារម្មណ៍ បាន ២៥ យ៉ាង គឺ រូបាវចរបឋមជ្ឈានចិត្ត ៣ មានអារម្មណ៍២៥ គឺ កសិណប្បញ្ញត្តិ ១០ អសុភបញ្ញត្តិ ១០ កោដ្ឋាសប្បញ្ញត្តិ ១ អានាបានប្បញ្ញត្តិ ១ បិយមនាបសត្តប្បញ្ញត្តិ ១ ទុក្ខិតសត្តប្បញ្ញត្តិ ១ និងសុខិតសត្តប្បញ្ញត្តិ ១ ជាអារម្មណ៍ ។

៨-ចិត្ត ៦ ទទួលអារម្មណ៍ បានគ្រប់យ៉ាង គឺ មនោទ្វារាវជ្ជនចិត្ត ១ មហាកិរិយាញាណសម្បយុត្តចិត្ត៤ កិរិយាអភិញ្ញាចិត្ត១

## ចប់ អារម្មណសង្គហៈ

# ៦-វត្ថុសង្គហៈ

ការរួបរួមចិត្ត និងចេតសិកទាំងឡាយ ដោយប្រភេទនៃវត្ថុ ឈ្មោះថា វត្ថុសង្គហៈ (វត្ថុ+សង្គហៈ)

**វត្ថុមាន ៦ គឺ**

១-ចក្ខុវត្ថុ បានដល់ ចក្ខុប្រសាទរូប

២-សោតវត្ថុ បានដល់ សោតប្រសាទរូប

៣-ឃានវត្ថុ បានដល់ ឃានប្រសាទរូប

៤-ជិវ្ហាវត្ថុ បានដល់ ជិវ្ហាប្រសាទរូប

៥-កាយវត្ថុ បានដល់ កាយប្រសាទរូប

៦-ហទយវត្ថុ បានដល់ ហទយរូប

**វត្ថុ** មានវិចនត្ថៈថា **វសន្តិ ចិត្តចេតសិកា ឯត្ថាតិ = វត្ថុ** ចិត្តនិងចេតសិកទាំងឡាយ រមែងនៅអាស្រ័យក្នុងធម្មជាតិនេះ ព្រោះហេតុនោះ ធម្មជាតិនេះ ទើបឈ្មោះថា វត្ថុ គឺ ធម្មជាតិជាទីអាស្រ័យកើតឡើងនៃចិត្តនិងចេតសិក ។ (**វស** ធាតុ ថុ បច្ច័យ, ប្តូរ **ស** > **ត** = **វត្ថុ**) ។

វត្ថុ កាលសម្តែងដោយវោហារហើយ ដូចផែនដី ជាទីតាំង ជាទីអាស្រ័យកើតឡើងនៃរបស់ទាំងឡាយគ្រប់យ៉ាង មានភ្នំ ដើមឈើជាដើម យ៉ាងណា វត្ថុដែលជាទីអាស្រ័យកើតឡើងនៃ ចិត្តនិងចេតសិកទាំងឡាយ ក៏យ៉ាងនោះ ។

ក្នុងបញ្ចវោការភូមិ(ភូមិដែលមានខន្ធ ៥) ចិត្ត និង ចេតសិកដែលនឹងត្រូវកើតឡើង ក៏ត្រូវអាស្រ័យហេតុ បច្ច័យ ៣ យ៉ាង គឺ អតីតកម្ម១ វត្ថុ១ អារម្មណ៍១ ទើបកើតឡើង ។

ចំណែកក្នុងចតុវោការភូមិ (ភូមិដែលមានខន្ធ ៤) ចិត្ត និងចេតសិក អាស្រ័យអតីតកម្ម និងអារម្មណ៍ រួមទាំង ២ យ៉ាង កើតឡើង ។

## សង្គហគាថា

១៣. ឆវត្ថុនិស្សិតា កាមេ សត្ត រូបេ ចតុព្វិធា
តិវត្ថុនិស្សិតារុប្បេ ធាត្វេកានិស្សិតា មតា ។

**គប្បីជ្រាបថា វិញ្ញាណធាតុ ៧ អាស្រ័យវត្ថុ ៦ កើតឡើងក្នុងកាមភូមិ ។ វិញ្ញាណធាតុ ៤ អាស្រ័យវត្ថុ ៣**

**កើតឡើងក្នុងរូបភូមិ ។ វិញ្ញាណធាតុ ១ មិនអាស្រ័យវត្ថុរូបទេ រមែងកើតឡើងក្នុងអរូបភូមិ ។**

## អធិប្បាយ

១-ឆ **វត្ថុនិស្សិតា កាមេ សត្ត** វិញ្ញាណធាតុ ៧ យ៉ាង អាស្រ័យវត្ថុ ៦ កើតឡើងក្នុងកាមភូមិ ១១ តាមសមគួរ គឺ -

១-ចក្ខុវិញ្ញាណធាតុ ២ អាស្រ័យចក្ខុវត្ថុកើតឡើង

២-សោតវិញ្ញាណធាតុ ២ អាស្រ័យសោតវត្ថុកើតឡើង

៣-ឃានវិញ្ញាណធាតុ ២ អាស្រ័យឃានវត្ថុកើតឡើង

៤-ជិវ្ហាវិញ្ញាណធាតុ ២ អាស្រ័យជិវ្ហាវត្ថុកើតឡើង

៥-កាយវិញ្ញាណធាតុ ២ អាស្រ័យកាយវត្ថុកើតឡើង

៦-មនោធាតុ ៣ អាស្រ័យហទយវត្ថុកើតឡើង

៧-មនោវិញ្ញាណធាតុ ៦៧ អាស្រ័យហទយវត្ថុកើត គឺ -

កាមចិត្តដែលនៅសល់ ៤១ មហគ្គតកុសលចិត្ត ៩

មហគ្គតកិរិយាចិត្ត ៩ លោកុត្តរចិត្ត ៨

២-**រូបេ ចតុព្វិធា តិវត្ថុនិស្សិតា** វិញ្ញាណធាតុ ៤ យ៉ាង

អាស្រ័យវត្ថុ ៣ កើតឡើងក្នុងរូបភូមិ ១៥ គឺ -

១-ចក្ខុវិញ្ញាណធាតុ ២ អាស្រ័យចក្ខុវត្ថុកើត

២-សោតវិញ្ញាណធាតុ ២ អាស្រ័យសោតវត្ថុកើត

៣-មនោធាតុ ៣ អាស្រ័យហទយវត្ថុកើត

៤-មនោវិញ្ញាណធាតុ ៦៧ អាស្រ័យហទយវត្ថុកើត គឺ

លោភមូលចិត្ត៨ មោហមូលចិត្ត២ សន្តីរណចិត្ត៣ កុសលចិត្ត៨ មហាកិរិយាចិត្ត៨ រូបាវចរចិត្ត១៥ អរូបាវចរកុសលចិត្ត៤ អរូបាវចរកិរិយាចិត្ត៤ លោកុត្តរចិត្ត៨

**៣-អរូបេ្ប ធាតុកោ និស្សិតា** វិញ្ញាណធាតុ ១ យ៉ាងមិនអាស្រ័យវត្ថុទេ រមែងកើតឡើងក្នុងអរូបភូមិ ៤ មានចិត្ត ៤៦ គឺ លោភមូលចិត្ត ៨ មោហមូលចិត្ត ២ មនោទ្វារាវជ្ជនចិត្ត[១] ១ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អរូបាវចរចិត្ត

---

១. <u>**ចំណាំ**</u> អហេតុកកិរិយាចិត្តទាំង៣ សរសេរតាមកិច្ច (ក្នុងអដ្ឋកថា ដីកាក៏មាន) ដើម្បីសម្រួលពាក្យឱ្យខ្លី

១២ លោកុត្តរចិត្ត ៧ (វៀរបឋមមគ្គ) ។

## សង្គហគាថា

១៤. គេបត្ថាឡីស និស្សាយ ទ្វេចត្តាឡីស ជាយរេ
អនិស្សាយ ច និស្សាយ បាការុបា អនិស្សិតា ។

ចិត្ត ៤៣ អាស្រ័យវត្ថុកើតប្រាកដ. ចិត្ត ៤២ អាស្រ័យវត្ថុកើត ខ្លះ មិនអាស្រ័យខ្លះ. អរូបវិបាកចិត្ត ៤ មិនអាស្រ័យវត្ថុឡើយ ក៏គង់កើតឡើង ។

## អធិប្បាយសង្គហគាថា

១-ចិត្ត ៤៣ អាស្រ័យវត្ថុកើតឡើងប្រាកដ គឺ -

ទ្វិបញ្ចវិញ្ញាណ ១០ កើតអាស្រ័យវត្ថុ ៥ ;

មនោធាតុ ៣ សន្តីរណចិត្ត ៣ ហសិតុប្បាទចិត្ត ១ ទោសមូលចិត្ត ២ មហាវិបាកចិត្ត ៨ រូបាវចរចិត្ត ១៥ សោតាបត្តិមគ្គចិត្ត ១ ទាំងនេះកើតឡើងអាស្រ័យហទយវត្ថុ ។

២-ចិត្ត ៤២ អាស្រ័យវត្ថុកើតខ្លះ មិនអាស្រ័យខ្លះ គឺ

អកុសលចិត្ត១០ (វៀរទោសៈ២) មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អរូបកុសលចិត្ត ៤ អរូបកិរិយាចិត្ត ៤ លោកុត្តរចិត្ត ៧ (វៀរបឋមមគ្គ) ។

៣-អរូបវិបាកចិត្ត ៤ កើតក្នុងអរូបភូមិ ៤ ដោយមិនត្រូវអាស្រ័យ វត្ថុរូបកើត ។

សរុបចិត្តដែលត្រូវអាស្រ័យវត្ថុនិងទ្វារ មាន ៤ យ៉ាង គឺ

១- ចិត្តដែលត្រូវអាស្រ័យទាំងវត្ថុ ទាំងទ្វារ មាន ៣៨
២- ចិត្តដែលអាស្រ័យវត្ថុ មិនអាស្រ័យទ្វារ មាន ៥
៣- ចិត្តដែលមិនអាស្រ័យវត្ថុ តែអាស្រ័យទ្វារ មាន ៤២
៤- ចិត្តដែលមិនអាស្រ័យទាំងវត្ថុ ទាំងទ្វារ មាន ៤ ។

## អធិប្បាយ

១-ចិត្ត ៣៨ ដែលត្រូវអាស្រ័យទាំងវត្ថុ ទាំងទ្វារកើត គឺ ទោសមូលចិត្ត ២, អហេតុកចិត្ត ១៧ (វៀរមនោទ្វារាវជ្ជនចិត្ត), មហាវិបាកចិត្ត ៨, រូបាវចរកុសលចិត្ត ៥, រូបាវចរ

កិរិយាចិត្ត ៥, សោតាបត្តិមគ្គចិត្ត ១,

បើរាប់ដោយពិស្តារ មិនស្មើគ្នាទេ គឺ

ក-ចិត្តដែលអាស្រ័យវត្ថុ ៦ កើត គឺ

-ទ្វិបញ្ចវិញ្ញាណ ១០ នេះ អាស្រ័យចក្ខុសោតឃានជិវ្ហាកាយវត្ថុ

-ចិត្ត ៧៥ អាស្រ័យហទយវត្ថុកើត

-អរូបវិបាកចិត្ត ៤ មិនអាស្រ័យហទយវត្ថុរូបកើត

ខ-ចិត្តដែលអាស្រ័យទ្វារ ៦ កើតឡើង គឺ -

-ចិត្ត ៤៦ អាស្រ័យចក្ខុទ្វារកើតឡើង

-ចិត្ត ៤៦ អាស្រ័យសោតទ្វារកើតឡើង

-ចិត្ត ៤៦ អាស្រ័យឃានទ្វារកើតឡើង

-ចិត្ត ៤៦ អាស្រ័យជិវ្ហាទ្វារកើតឡើង

-ចិត្ត ៤៦ អាស្រ័យកាយទ្វារកើតឡើង

-មហគ្គតវិបាកចិត្ត ៩ មិនអាស្រ័យទ្វារកើតឡើង ។

២-ចិត្តដែលអាស្រ័យវត្ថុ មិនអាស្រ័យទ្វារ គឺ រូបាវចរ

វិបាកចិត្ត ៥

កាលដែលរូបព្រហ្មបុគ្គលបដិសន្ធិដោយចិត្ត ៥នេះ ណាមួយ សុទ្ធតែជាអញ្ញមញ្ញប្បច្ច័យជាមួយនឹងហទយវត្ថុ ដោយមិនអាស្រ័យទ្វារកើតឡើង ហៅថា **ទ្វារវិមុត្តចិត្ត ។**

៣-ចិត្ត ៤២ ដែលមិនអាស្រ័យវត្ថុ តែអាស្រ័យទ្វារ គឺ អកុសលចិត្ត ១០ ( វៀរទោសមូលចិត្ត ២ ) មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អរូបកុសលចិត្ត ៤ អរូបកិរិយាចិត្ត ៤ លោកុត្តរចិត្ត ៧ ( វៀរបឋមមគ្គ ) ចិត្តទាំង ៤២ នេះ កាលកើតជាមួយអរូបព្រហ្មបុគ្គល មិនអាស្រ័យវត្ថុរូបកើត និងកើតតាមផ្លូវមនោទ្វារតែម្យ៉ាង ។

៤-ចិត្តដែលមិនអាស្រ័យទាំងវត្ថុ មិនអាស្រ័យទាំងទ្វារគឺ អរូបាវចរវិបាកចិត្ត ៤ ។

## ចេតសិក ៥២

ចេតសិកដែលអាស្រ័យវត្ថុ និងទ្វារ ដោយឯកន្តៈ ( ពិតប្រាកដ ) និង អនេកន្តៈ ( មិនពិតប្រាកដ ) ដូច្នេះ គឺ -

១-ចេតសិកដែលកើតក្នុងទ្វិបញ្ចវិញ្ញាណ១០, ជាអនេកន្ត:

២-ចេតសិកដែលអាស្រ័យហទយវត្ថុ ដោយឯកន្តៈ មាន ៦ គឺ ទោចតុក្កចេតសិក ៤ (ក្នុងកាមភូមិ) អប្បមញ្ញាចេតសិក ២ (ក្នុងបញ្ចវោការភព)

ចេតសិក ៤៦ ដែលនៅសល់ ជាអនេកន្តៈ ។

មួយទៀត ក្នុងគម្ពីរសេចក្ដីសង្ខេប សម្ដែងចិត្ត ៣ភូមិ គឺ

**១-ឯកដ្ឋចិត្ត** ចិត្តដែលកើតបាន តែមួយភូមិ

**២-ទ្វិដ្ឋចិត្ត** ចិត្តដែលកើតបានក្នុង ២ ភូមិ

**៣-តិដ្ឋចិត្ត** ចិត្តដែលកើតបានក្នុង ៣ ភូមិ

១-ចិត្តដែលកើតបានក្នុងភូមិតែមួយ មាន ២៥ គឺ -

-ឃានវិញ្ញាណ២ ជិវ្ហាវិញ្ញាណ២ កាយវិញ្ញាណ២

មហាវិបាកចិត្ត៨ បដិឃសម្បយុត្តចិត្ត២

កើតបានក្នុងកាមភូមិ

-មហគ្គតវិបាកចិត្ត ៩ កើតបានក្នុងរូប-អរូបភូមិ

២-ចិត្តដែលកើតបាន ២ភូមិ (កាមភូមិ, រូបភូមិ) មាន

២២ គឺ ចក្ខុវិញ្ញាណ២ សោតវិញ្ញាណ២ វិបាកមនោធាតុ២ សន្តីរណចិត្ត៣ បញ្ចទ្វារាវជ្ជនចិត្ត១ ហសិតុប្បាទចិត្ត១ ជវនចិត្តក្នុងរូបាវចរចិត្ត១០ សោតាបត្តិមគ្គចិត្ត១ ។

៣-ចិត្តដែលកើតបាន ៣ ភូមិ មាន ៤២ គឺ អកុសលចិត្ត ១០ (វៀរទោសមូលចិត្ត ២) មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អរូបកុសលចិត្ត ៤ អរូបកិរិយាចិត្ត ៤ លោកុត្តរចិត្ត ៧ (វៀរបឋមមគ្គ) ។

**ចប់ វត្ថុសង្គហៈ**

**អវសានគាថា**

ឥច្ចានុរុទ្ធ រចិតេ អភិធម្មត្ថសង្គហេ
តតិយោ បរិច្ឆេទោយំ សមាសេនេវ និដ្ឋិតោ ។

បរិច្ឆេទទី ៣ នេះ ឈ្មោះថា បកិណ្ណកសង្គហៈដែលព្រះអនុរុទ្ធាចារ្យ បានរចនាទុកក្នុងបករណអភិធម្មត្ថសង្គហៈ ចប់តែប៉ុណ្ណោះហោង ។

# សម្ដែងបកិណ្ណកសង្គហៈ ៦ យ៉ាង

- ១-សង្គ្រោះវេទនា ៣ ឬ ៥
  - សុខវេទនា៦៣
    - សុខិន្ទ្រិយ ១
    - សោមនស្សិន្ទ្រិយ ៦២
  - ទុក្ខវេទនា៣
    - ទុក្ខិន្ទ្រិយ ១
    - ទោមនស្សិន្ទ្រិយ២
  - ឧបេក្ខាវេទនា ឬ ឧបេក្ខិន្ទ្រិយ ៥៥
- ២-សង្គ្រោះហេតុ ៦
  - ចែកចិត្តដោយហេតុ
    - អហេតុកចិត្ត ១៨
    - ឯកហេតុកចិត្ត ២
    - ទ្វិហេតុកចិត្ត ២២
    - តិហេតុកចិត្ត ៤៧ ឬ ៧៩
  - ចែកចេតសិកដោយហេតុ
    - ឯកហេតុកចេតសិក ៣
    - ទ្វិហេតុកចេតសិក ៩
    - តិហេតុកចេតសិក ២៧
    - បញ្ចហេតុកចេតសិកមាន ១
    - ឆហេតុកចេតសិកមាន ១២

**៣-សង្គ្រោះកិច្ច ១៤ ឋាន ១០**

- កិច្ច ១ និងឋាន ១ មាន ៦៨
- កិច្ច ២ និងឋាន ២ មាន ២
- កិច្ច ៣ និងឋាន ៣ មាន ៩
- កិច្ច ៤ និងឋាន ៤ មាន ៨
- កិច្ច ៥ និងឋាន ៥ មាន ២

**៤-សង្គ្រោះទ្វារ ៦ និងទ្វារវិមុត្ត**

- ឯកទ្វារិកចិត្ត ៣៦
- បញ្ចទ្វារិកចិត្ត ៣
- ឆទ្វារិកចិត្ត ៣១
- ឆទ្វារិកវិមុត្តចិត្ត ១០
- ឆទ្វារិកវិមុត្តចិត្ត សព្វថា ៩

៥-សង្គ្រោះអារម្មណ៍
- អារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម
- ឥដ្ឋារម្មណ៍ ២
- ចែកអារម្មណ៍ដោយកាល ៤
- អារម្មណ៍ដោយសង្ខេប ៤
- អារម្មណ៍ ៧
- អារម្មណ៍ដោយពិស្តារ ២១
- ចិត្តទទួលអារម្មណ៍ ២១
- ចេតសិកទទួលអារម្មណ៍ ២២
- ចិត្តដឹងអារម្មណ៍ ៨ ន័យ

៦-សង្គ្រោះវត្ថុ
- វត្ថុរូប ៦
- ចែកវិញ្ញាណធាតុដោយវត្ថុតាមភូមិ ៤
- ចិត្តអាស្រ័យវត្ថុនិងទ្វារ ៤ យ៉ាង
- ចេតសិកអាស្រ័យវត្ថុ និងទ្វារ ២ យ៉ាង
- សម្តែងចិត្ត ៣ ភូមិ

**បរិច្ឆេទទី ៣ បកិណ្ណកសង្គហវិភាគ ចប់**

យំ ឯត្ថ វុឌ្ឍិមន្តោ សលក្ខណា បូជិតា បរិច្ឆិន្នា
វុត្តាធិកា ច ធម្មា អភិធម្មោ តេន អក្ខាតោ ។
ព្រោះហេតុដែលធម៌ទាំងឡាយ មានសេចក្តីចម្រើន
មានការកំណត់ ជាធម៌ដែលបុគ្គលបូជាហើយ ជាធម៌
ដែលបណ្ឌិតកាត់ជាចំណែកៗ និងជាធម៌ដ៏ក្រៃលែង
ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ក្នុងព្រះ
អភិធម្មនេះ ដូច្នោះ ទើបលោកពោលថា អភិធម្ម ។



ភិក្ខុ អគ្គធីរោ គង់ សុមិត្ត